# មុខវិជ្ជាៈ
# ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ

## កញ្ចប់សមត្ថភាពទី ២
## ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជាការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំផ្តោតលើការប្រើប្រាស់ចំណេះដឹងនៃការគ្រប់គ្រង និងអភិវឌ្ឍធានធានបុគ្គលិក ក្នុងដំណើរការគ្រប់គ្រងសាលារៀន ដែលមានគោលបំនងបណ្តុះបណ្តាលឱ្យអ្នកសិក្សាមានសមត្ថភាព ដូចជា យល់ដឹង និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់បុគ្គលិកនៅតាមសាលារៀន និងនៅក្នុងស្ថាប័នរបស់ខ្លួន និងអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់បុគ្គលិក ការអភិវឌ្ឍកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំការត្រួតពិនិត្យឡើងវិញជាឆមាសនិងប្រចាំឆ្នាំ និងការសរសេរនិងត្រួតពិនិត្យលទ្ធផលឡើងវិញដើម្បីដាក់ជារង្វាន់ឬទណ្ឌកម្មដល់បុគ្គលិក។

**លទ្ធផលសិក្សារំពឹងទុកៈ**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹងៈ*

លទ្ធផលសិក្សារំពឹងទុកទី ១ៈបង្ហាញការយល់ដឹងអំពីបញ្ញត្តិ និងគោលការណ៍នៃការគ្រប់គ្រងបុគ្គលិកនៅសាលារៀន

លទ្ធផលសិក្សារំពឹងទុកទី ២ៈពន្យល់ពីមធ្យោបាយអភិវឌ្ឍធនធានមនុស្សនៅសាលារៀន

លទ្ធផលសិក្សារំពឹងទុកទី ៣ៈអនុវត្តយន្តការនៃការដឹកនាំ និងការគ្រប់គ្រងបុគ្គលិកផ្អែកលើលទ្ធផលការងារ

លទ្ធផលសិក្សារំពឹងទុកទី ៤ៈរៀបចំកិច្ចព្រមព្រៀងប្រចាំឆ្នាំរបស់បុគ្គលិកនិងតាមដានការបំពេញការងារតាមកិច្ចព្រមព្រៀងប្រចាំឆ្នាំ

លទ្ធផលសិក្សារំពឹងទុកទី ៥ៈ អភិវឌ្ឍឥរិយាបថក្នុងការបំពេញការងារបុគ្គលិកប្រកបដោយស្មារតីក្រុម ការទទួលខុសត្រូវ និងការច្នៃប្រឌិត

**វាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្រ្តកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្រ្ត និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្រ្តសហគមន៍សាលារៀនជាយុទ្ធសាស្រ្តស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្រ្តរយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្រ្តសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្រ្តសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២២
**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

# អនុវត្ត រៀនសូត្រ សម្របនិងឆ្លើយតបតាមតម្រូវការសិក្សា អភិវឌ្ឍ តាមការអភិវឌ្ឍ នវានុវត្តន៍ ដោះស្រាយជាបន្ត នូវភាពក្រីក្ររៀនសូត្រ ភាពក្រីក្រសង្គម និង ភាពក្រីក្ររូបិយវត្ថុ»

"Apply, Learn, Adapt, Teach, and Develop Addressing Learning Poverty, Social Poverty, and Monetary Poverty"

## ព័ត៌មានសង្ខេប

| កម្មវិធីសិក្សា | |
|---|---|
| ក្របខណ្ឌគុណវុឌ្ឍិ | កម្រិត ៧/ កម្រិតសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ |
| មហាវិទ្យាល័យ | មហាវិទ្យាល័យអប់រំ |
| កម្មវិធី | កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន |
| ឯកទេស ឬជំនាញ | (១)ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀនកម្រិតមធ្យមសិក្សា |
| ចំនួនក្រេឌីត | ៤៨ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១៧ មីនា ២០២៣ |

## ឈ្មោះកម្មវិធី និងសញ្ញាបត្រ

ឯកទេសបរិញ្ញាបត្រជាន់ខ្ពស់អប់រំសម្រាប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន

| កម្រិតសញ្ញាបត្រ | ឯកទេស |
|---|---|
| បរិញ្ញាបត្រជាន់ខ្ពស់អប់រំ<br>Master of Education<br>(M.Ed) | ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀនកម្រិតមធ្យមសិក្សា<br>(Educational Administration and School Community Strategy in Secondary Education) |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (២) ចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន (៣) ហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង។ កញ្ចប់សមត្ថភាពទាំងបីខាងលើនឹងជួយឱ្យគរុនិស្សិត អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងអភិពង្រឹងសមត្ថភាពផ្នែក (ក) ការសម្រេចចិត្ត ទំនាក់ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ។ ដូចគ្នាផងដែរ កញ្ចប់សមត្ថភាពបីខាងលើ នឹងនាំឱ្យអ្នកសិក្សាអភិវឌ្ឍសមត្ថភាពផ្នែក (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




## សម្រាប់ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀន (មធ្យមសិក្សា)

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍ សាលារៀនត្រូវបានកំណត់ដូចខាងក្រោម៖

***ចំណេះដឹង/វិជ្ជាសម្បទា***

PLO1-A ពន្យល់ស៊ីជម្រៅអំពីទ្រឹស្តី ទស្សនាទាន និងគោលការណ៍នៃការអប់រំក្នុងបរិបទសាកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែង។

PLO2-A បកស្រាយស៊ីជម្រៅអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកសាលារៀនឱ្យមានសមត្ថភាពអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនប្រកបដោយប្រសិទ្ធភាព។

PLO3-A យល់ដឹងស៊ីជម្រៅអំពីបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- ប្រើប្រាស់យន្តការ និងមធ្យោបាយសម្រាប់ដឹកនាំ និងគ្រប់គ្រងសាលារៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា និងការអនុវត្តជាក់ស្តែង។

PLO5- អនុវត្តការងារដឹកនាំ ការងារគ្រប់គ្រង ការងារប្រឹក្សាគរុកោសល្យ កម្មវិធីរកចំណូល និងកម្មវិធីជានាវ៉ាប់រងសង្គមសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ឥរិយាបថ/ចរិយាសម្បទា***

PLO6-A មានឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7-A សហការណ៍ជាមួយបណ្ដាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការគ្រប់គ្រងអប់រំ។

PLO8-A មានជំនាញឌីជីថល និងជំនាញទន់ដទៃទៀត

***ជំនាញ/បំណិនសម្បទា***

..........................................

## អាជីពអនាគត

ឱកាសការងារសម្រាប់អ្នកដែលបញ្ចប់ការសិក្សាដោយជោគជ័យពីកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំសម្រាប់អនុវិស័យមធ្យមសិក្សាតាមការជ្រើសរើសឯកទេសរបស់និស្សិត/អ្នកសិក្សា៖

*សម្រាប់ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀន*

- នាយកសាលារៀន/គណៈគ្រប់គ្រងសាលារៀន
- មន្ត្រីអប់រំផ្នែកដឹកនាំ និងគ្រប់គ្រង
- ទីប្រឹក្សាគរុកោសល្យសម្រាប់គណៈគ្រប់គ្រងសាលារៀន
- អ្នកអប់រំសហគ្រិនភាព
- អ្នកស្រាវជ្រាវផ្នែកភាពអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំ

## លក្ខខណ្ឌនៃការជ្រើសរើសចូលសិក្សា

ការដាក់ពាក្យចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំដូចបានកំណត់ខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្រអប់រំពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន
- មានចំណេះដឹងភាសាអង់គ្លេស
- ទទួលលទ្ធផលជាប់ក្នុងការប្រឡងចូលសិក្សា

## លក្ខខណ្ឌតម្រូវសម្រាប់បញ្ចប់ការសិក្សា និងច្រកចេញដើម្បីទទួលគុណវុឌ្ឍិ

ក្រោយពីបំពេញគ្រប់លក្ខខណ្ឌក្នុងការបញ្ចប់ការសិក្សាដោយជោគជ័យ និស្សិត/អ្នកសិក្សានឹងទទួលបានសញ្ញាបត្រកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំតាមឯកទេសដែលនិស្សិត/អ្នកសិក្សាបានជ្រើសរើសដែលចេញដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីបញ្ចប់ការសិក្សាដោយជោគជ័យ និស្សិត/អ្នកសិក្សាត្រូវគោរពតាមបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បង្ហាញវត្តមាន (ដោយផ្ទាល់ និងពីចម្ងាយ/អនឡាញ)យ៉ាងតិច ៧០%
- បំពេញការសិក្សាមុខវិជ្ជាឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ២៧ ក្រេឌីត
- បំពេញមុខវិជ្ជាចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន ៩ (+៣) ក្រេឌីត
- ហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង ៩ ក្រេឌីត

## កញ្ចប់សមត្ថភាព និងរចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំមានចំនួន ៤៨ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទ។ អ្នកសិក្សានឹងបញ្ចប់ការសិក្សាតាមរយៈការសិក្សា និងការស្រាវជ្រាវ។ អ្នកសិក្សាតម្រូវឱ្យសិក្សាមុខវិជ្ជាឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៧ ក្រេឌីត មុខវិជ្ជាចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀនចំនួន ៩ (+៣) ក្រេឌីត មុខវិជ្ជាហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង ចំនួន ៩ ក្រេឌីត។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ និក្ខេបបទតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់(៦០%) | ៩ | ២៧ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន (២០%) | ៣(+១) | ៩ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ | ៩ |
| សរុប | ១៦ | ៤៨ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




២. មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជា | ក្រេឌីត |
|---|---|---|
| (១) ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (៦០%) ២៧ ក្រេឌីត | ចិត្តវិទ្យាអប់រំកម្រិតខ្ពស់ ១ | ៣ |
| | ចិត្តវិទ្យាអប់រំកម្រិតខ្ពស់ ២ | ៣ |
| | ការគ្រប់គ្រងវង្វាយតម្លៃអប់រំ | ៣ |
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀនកម្រិតខ្ពស់ | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន សម្រាប់មធ្យមសិក្សា | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | មូលដ្ឋានគ្រឹះការបង្វឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | ការធ្វើផែនការបង្វឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | វិធីសាស្ត្របង្វឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | ការអនុវត្តលើកម្មវិធីរកចំណូលនៅគ្រឹះស្ថានសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |

| | | |
|---|---|---|
| (២) ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងគ្រប់គ្រងតាមសាលារៀន (២០%) ៩(+៣) ក្រេឌីត | ការគ្រប់គ្រងគុណផលបុគ្គលិកសម្រាប់យុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | បច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | (+៣) |
| (៣) ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) ៩ ក្រេឌីត | កម្មសិក្សាសម្រាប់បទពិសោធវិជ្ជាជីវៈនៅសាលាមធ្យមសិក្សា | ៣ |
| | ការសរសេរនិក្ខេបបទ | ៣ |
| | ការការពារនិក្ខេបបទ | ៣ |
| **សរុប** | | **៤៨** |

## ស្តង់ដាសាលារៀនមានប្រសិទ្ធភាព

ដើម្បីសម្រេចសូចនាករគម្រោង ដែលមានពិន្ទុនៃការកែប្រែរបៀបគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងការបង្រៀន ការបណ្តុះបណ្តាលកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ក្នុងគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាប្រើប្រាស់ស្តង់ដាទាំងប្រាំដែលមានចែងក្នុង សៀវភៅណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ ជាគោល។

| លរ | ស្តង់ដាសាលារៀនមានប្រសិទ្ធិភាព | ពិន្ទុអប្បបរមា | ពិន្ទុអតិបរមា | អ្នកទទួលបន្ទុកបង្គោល |
|---|---|---|---|---|
| ១ | សាលារៀនមានដំណើរការសម្រេចផលសម្រេចអប់រំ និងការសិក្សារៀនសូត្ររបស់សិស្ស (ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ) | ៣៩ | ៥២ | គណៈគ្រប់គ្រង |
| ២ | ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ | ៤៧ | ៦៤ | គ្រូបង្រៀន |
| ៣ | ភាពជាម្ចាស់នៃសហគមន៍សាលារៀន | ៤៨ | ៦៤ | គណៈកម្មការគ្រប់គ្រងសាលារៀន |
| ៤ | ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | ៤៨ | ៦៤ | គណៈគ្រប់គ្រង |
| ៥ | គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | ២៧ | ៣៦ | ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ពិន្ទុសរុប | | ២១០ | ២៨០ | |

ក្នុងការបណ្ដុះបណ្ដាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| ល.រ | កិច្ចការ |
|---|---|
| ១ | តេស្តស្តង់ដាចុងឆ្នាំ និងដើមឆ្នាំ |
| ២ | តេស្តស្តង់ដាប្រចាំខែ និងត្រីមាស |
| ៣ | ប្រមូលសិស្សចូលរៀន (ផែនទីខ្នងផ្ទះ និងស្ថិតិគ្រួសារ) |
| ៤ | គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងសាលារៀន |
| ៥ | ផែនការ៦ឆ្នាំ ៣ឆ្នាំ ១ឆ្នាំ ថ្នាក់រៀន និងសិស្ស |
| ៦ | កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង |
| ៧ | ប្រជុំពិនិត្យតាមដានប្រចាំខែ និងត្រីមាស |
| ៨ | ពិនិត្យតាមដាន និងគាំទ្រការបង្រៀនរបស់គ្រូបង្រៀន (អធិការកិច្ចការបង្រៀនរបស់គ្រូបង្រៀន) |
| ៩ | វាយតម្លៃសាលារៀនជាប់ស្តង់ដាសាលារៀនមានប្រសិទ្ធភាព |

## ដំណើរការអនុវត្តកម្មវិធីសិក្សា

ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ប្រព័ន្ធក្រេឌីត និងគោលការណ៍ច្បាប់របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលអនុលោមតាមបទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តកម្មវិធីសិក្សាអាចមានលក្ខណៈបត់បែនដោយឈរលើមូលដ្ឋាននៃការផ្តោតលើផលសម្រេចការសិក្សារបស់និស្សិត/អ្នកសិក្សាជាចម្បង។

## ការអនុវត្តប្រព័ន្ធក្រេឌីត

ការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះមាន៤៨ ក្រេឌីត។ យោងសេចក្តីសម្រេចលេខ ០៤/០៤ គ.ទ.ក.ស.ស.រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរការសិក្សា ការសិក្សា ១ ក្រេឌីតស្មើនឹង ៤៥ ម៉ោងនៃការសិក្សានៅក្នុងថ្នាក់ និងនៅក្រៅថ្នាក់។ ចំនួនម៉ោងសិក្សាអាចប្រែប្រួលទៅតាមនៃមុខវិជ្ជាសិក្សា ដូចបង្ហាញខាងក្រោម៖

- ការឧទ្ទេស៖ ១ ក្រេឌីតសម្រាប់ការឧទ្ទេសមាន ១៥ម៉ោងសិក្សាក្នុងថ្នាក់រៀននិង៣០ម៉ោងសិក្សាក្រៅថ្នាក់
- ការសិក្សាដោយពិសោធន៍/សិក្ខាសាលា៖ ១ ក្រេឌីត សមមូលនឹងការធ្វើពិសោធន៍ ៣០ម៉ោងនៅក្នុងមន្ទីរពិសោធន៍ ឬការបណ្ដុះបណ្ដាល ៣០ ម៉ោងតាមរយៈសិក្ខាសាលា និង១៥ម៉ោងនៃការសិក្សាក្រៅមន្ទីរពិសោធន៍ ឬចូលរួមសិក្ខាសាលា
- ការធ្វើកម្មសិក្សា៖ ១ ក្រេឌីត មាន ៤៥ម៉ោងនៃការបណ្ដុះបណ្ដាលដែលបានធ្វើឡើងនៅក្នុងកសិដ្ឋាន/កន្លែងអនុវត្តការងារ និងនៅទីកន្លែងដែលពាក់ព័ន្ធផ្សេងទៀត។

ដោយអនុវត្តតាមប្រព័ន្ធក្រេឌីត និស្សិត/អ្នកសិក្សាអាចជ្រើសរើសមុខវិជ្ជាសិក្សាតាមពេលវេលាជាក់ស្តែងក្នុងរយៈពេលកំណត់នៃកម្មវិធីអប់រំ។

## រយៈពេលសិក្សា

កម្មវិធីអប់រំសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះអាចមានរយៈពេលសិក្សារហូតដល់៣៦ ខែ ឬ៣ ឆ្នាំសិក្សា។ និស្សិត/អ្នកសិក្សាអាចបញ្ចប់ការសិក្សាយូរឬឆាប់អាស្រ័យលើការលិខិតបំពេញការសិក្សាតាមចំនួនក្រេឌីតដែលបានកំណត់។

## ការអនុវត្តកម្មវិធីសិក្សា

ដំណើរការសិក្សាអាចធ្វើឡើងនៅក្នុងថ្នាក់ផ្ទាល់ ឬតាមរយៈការសិក្សាពីចម្ងាយឬអនឡាញន៍អាស្រ័យទៅតាមភាពជាក់ស្តែង។ ក្នុងការសិក្សា និស្សិត/អ្នកសិក្សាត្រូវបំពេញឱ្យគ្រប់ ៤៨ ក្រេឌីតសម្រាប់កម្មវិធីទាំងមូល ហើយអាចបំពេញ ១៥ ក្រេឌីតជាមធ្យមសម្រាប់ឆមាសនីមួយៗ។ កាលវិភាគសិក្សាមានលក្ខណៈបត់បែននឹងរៀបចំតាមតម្រូវការជាក់ស្តែង។

ការអនុវត្តកម្មវិធីសិក្សាមានសកម្មភាពដូចខាងក្រោមសម្រាប់សម្របសម្រួលជូននិស្សិត/អ្នកសិក្សា៖

- ការតម្រង់ទិសការសិក្សា និងកិច្ចការសម្រាប់អនុវត្តន៍
- ការសិក្សាមុខវិជ្ជាសិក្សាដែលមានទ្រឹស្តីភ្ជាប់នឹងការអនុវត្ត
- ការពិនិត្យតាមដានដំណើរសិក្សាមុខវិជ្ជាសិក្សា
- ការប្រឹក្សាយោបល់សម្រាប់ជួយដល់ដំណើរការសិក្សា
- ការសម្របសម្រួលដល់ការហាត់ការ/កម្មសិក្សា
- ការណែនាំអំពីនិក្ខេបបទ។

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរនិក្ខេបបទ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៧.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង ៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗតាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្មុលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារនិក្ខេបបទ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារនិក្ខេបបទ។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តការកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ការក្លែងបន្លំឯកសារ

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### របាយការណ៍/កិច្ចការស្រាវជ្រាវ

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិតសរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តន៍ជាក់ស្តែងដើម្បីឆ្លើយតបទៅនឹងស្ថានភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែងស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP ។

# ការគ្រប់គ្រង និងការ
# អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្ដេច?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្ដេច?

- ជាការសិក្សាដែលធ្វើឡើងជាប្រចាំដោយស្វ័យភាព និងដោយខ្លួនឯង
- ការសិក្សារៀនសូត្រស្រាវជ្រាវជាប្រចាំដើម្បីឱ្យខ្លួនឯងមានសមត្ថភាពកាន់តែប្រសើរ និងទាន់សម័យ
- គឺជាការពង្រីកសមត្ថភាពរបស់ខ្លួនលើជំនាញរបស់ខ្លួន តាមរយៈការចូលរួមសិក្ខាសាលា ឬកម្មវិធីសិក្សាផ្សេងទៀត
- ការពង្រឹងសមត្ថភាពផ្នែកវិជ្ជាជីវៈ ការស្រាវជ្រាវតាមអនឡាញ តាមបណ្ណាល័យ ឬវគ្គបណ្ដុះបណ្ដាលផ្សេងទៀតដើម្បីពង្រឹងសមត្ថភាពខ្លួន
- ការពង្រឹងឯកទេសតាមរយៈការចូលរួមកម្មវិធីសិក្សាដើម្បីមានចំណេះដឹងកើនឡើង
- បន្តការសិក្សាលើអាជីព និងជំនាញបន្ថែមលើចំណេះដឹងដែលមាន និងចាប់យកអ្វីដែលថ្មី ស្វែងរកការសិក្សាតាមប្រព័ន្ធអនឡាញ ចំណេះដឹងថ្មីៗដែលយើងមិនមាន ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួន បង្កើនបំណិនដើម្បីប្រសិទ្ធភាពទំនាក់ទំនងក្នុងការងារ។

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្ដេច?

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលបំណងក្នុងការរក្សាបាន និងការធ្វើបច្ចុប្បន្នកម្មចំណេះដឹង និងសមត្ថភាព ក៏ដូចជាការកែលម្អការអនុវត្តការងាររបស់បុគ្គលម្នាក់ៗ
- CPD គឺជាកាតព្វកិច្ចរបស់អង្គគ្រូបង្រៀនគ្រប់រូប
- តាម ត្រង់ទំព័រទី ៩៖



## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្តេច?

គោលនយោបាយ អវប ចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀន ដោយកំណត់ឱ្យចូលរួមនៅក្នុងសកម្មភាព អវប ចំនួន ១០០ម៉ោងក្នុងមួយឆ្នាំ ប្រហែលជា ៣ម៉ោងក្នុងមួយសប្តាហ៍។ គោលនយោបាយនេះផ្តល់អនុសាសន៍ឱ្យគ្រូបង្រៀនចំណាយពេលមិនបង្រៀន ៥ថ្ងៃក្នុងមួយឆ្នាំ ស្មើនឹង ៤០ម៉ោង មានន័យថា ចាំបាច់ត្រូវចំណាយពេលផ្ទាល់ខ្លួន ៦០ម៉ោងទៀតសម្រាប់ចូលរួមនៅក្នុងសកម្មភាព អវប ទើបអាចបាន ១០០ម៉ោង។ នៅក្នុងការអនុវត្តជាក់ស្តែង គ្រូបង្រៀនមានសិទ្ធិ និងលទ្ធភាព ចូលរួមនៅក្នុងសកម្មភាព អវប យ៉ាងហោចណាស់ ៣ម៉ោងក្នុងមួយសប្តាហ៍ ដោយប្រើប្រាស់ម៉ោងបំពេញការងារ ។ ឧទាហរណ៍ គ្រូបង្រៀនបឋមសិក្សាមិនបង្រៀននៅថ្ងៃព្រហស្បតិ៍សប្តាហ៍ទី៤ នៃខែនីមួយៗ ដែលជាថ្ងៃសម្រាប់ប្រជុំបច្ចេកទេស ប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈជួយសិស្សរៀនយឺតជាដើម ហើយផ្តល់ឱកាសឱ្យគ្រូបង្រៀនបឋមសិក្សាចូលរួមសកម្មភាព អវប រយៈពេល ៣ម៉ោងនៅក្នុងអំឡុងពេលនេះ។ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ បង្រៀន ១៨ម៉ោង និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិបង្រៀន ១៦ម៉ោង ដែលផ្តល់លទ្ធភាពឱ្យពួកគេមានពេល ៣ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីចូលរួមនៅក្នុងសកម្មភាព អវប។ ក្នុងករណីគ្រូបង្រៀន បង្រៀនពីរវេន នៅតាមសាលារៀនដែលជួបប្រទះនឹងការខ្វះគ្រូបង្រៀនអាចប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាព អវប ។ បន្ថែមលើកាតព្វកិច្ចចូលរួម សកម្មភាពអវប ១០០ម៉ោងក្នុងមួយឆ្នាំ ដើម្បីទទួលបានក្រេឌីតបន្ថែម គ្រូបង្រៀនដែលមានបំណងចូលរួម សកម្មភាព អវប ត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលចុងសប្តាហ៍ និងវិស្សមកាល។

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្តេច?

- តាមការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺជារបបបណ្តុះបណ្តាល ការស្រាវជ្រាវ និងការចូលរួមចំណែកក្នុងវិស័យវិជ្ជាជីវៈប្រតិបត្តិដល់បុគ្គលម្នាក់ ដោយផ្តោតលើការធ្វើបច្ចុប្បន្នកម្ម ការអភិវឌ្ឍ និងការធ្វើឱ្យប្រសើរឡើងសមត្ថភាព ចំណេះដឹង និងបំណិនរបស់បុគ្គល ឆ្លើយតបទៅតាមតម្រូវការវិជ្ជាជីវៈ។
- ក្នុងន័យនេះ យើងអាចបំបែកពាក្យដូចខាងក្រោម៖
- ការអភិវឌ្ឍ៖ ការធ្វើឱ្យប្រសើរឡើងនៃការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់បុគ្គល និងការធ្វើឱ្យមានការរីកចម្រើនសមត្ថភាពការងារ

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យដូចម្តេច?

- វិជ្ជាជីវៈ៖ គឺជាអ្វីដែលពាក់ព័ន្ធនឹងសមត្ថភាពរបស់បុគ្គលក្នុងការងារដែលខ្លួនទទួលខុសត្រូវ
- ប្រចាំ៖ ការសិក្សារៀនសូត្រគឺជាដំណើរការជាប្រចាំដែលមិនមានការបញ្ឈប់ដោយមិនគិតពីអាយុ ឬអតីតភាពនោះឡើយ។

សរុបមក ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យថា គឺជារបៀបដែលអ្នកអាជីពបន្តការសិក្សា និងការអភិវឌ្ឍខ្លួនឯងនៅពេលដែលការបណ្តុះបណ្តាលដំបូងរបស់ពួកគេបានបញ្ចប់។

តើយើងទាំងអស់គ្នាធ្លាប់ធ្វើវាដែរឬទេ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលដៅអ្វីខ្លះ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលដៅអ្វីខ្លះ?

- ធ្វើឡើងជាប្រចាំ ធ្វើស្វ័យភាព និងគ្រប់គ្រងការសិក្សាដោយខ្លួនឯង អនុវត្តផ្អែកតាមតម្រូវការ និងអនុវត្តតាមស្ថានភាពបច្ចុប្បន្នរបស់បុគ្គលម្នាក់ៗ
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំរបស់ខ្លួនឯង
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនក្នុងវិស័យអប់រំ ជំរុញអ្នកធ្វើឱ្យមានការទទួលបានឋានវិជ្ជាជីវៈ ឈានចូលគន្លងអាជីព គ្រូល្អ នាយកល្អ
- បង្កើនចំណេះដឹង ជំនាញរបស់ខ្លួនសម្រាប់បង្កើនចំណេះដឹងថ្មី ឆ្លើយតបតាមតម្រូវការទាន់សម័យ
- ជួយដល់គ្រូបង្រៀន គណៈគ្រប់គ្រងទទួលបានចំណេះដឹងថ្មី សមត្ថភាពកាន់តែប្រសើរជាងមុន
- កំណត់លទ្ធផលការសិក្សារៀនសូត្រ និងលទ្ធផលច្បាស់លាស់ឆ្លើយតបតាមតម្រូវការ
- ការកែលម្អជំនាញ និងចំណេះដឹង ត្រៀមខ្លួនជាស្រេចក្នុងការផ្លាស់ប្តូរ វិនិយោគក្នុងអាជីព ផ្តល់ការងារកាន់តែប្រសើរ កម្លាំងផ្ទាល់ខ្លួន
- ដើរតាមទាន់សិស្ស ធ្វើឱ្យចំណេះដឹងកាន់តែរីកចម្រើន ដើរតាមទាន់ប្រទេសដទៃ
- បណ្តុះស្មារតីចំពោះអាជីពរបស់ខ្លួន អភិវឌ្ឍចំណេះដឹងរបស់ខ្លួនដើម្បីដើរទាន់សម័យកាល ដើរទាន់ការងាររបស់ខ្លួន

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលបំណងអ្វីខ្លះ?

សម្រាប់បុគ្គល គោលបំណងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរួមមានធំៗដូចខាងក្រោម៖

- ធានាថាចំណេះដឹង សមត្ថភាព និងបំណិនមានបច្ចុប្បន្នភាព
- ធានាបានថាសមត្ថភាពខ្លួននៅលើការងារ
- មានសមត្ថភាពក្នុងការសម្រេចបាននូវកិច្ចការលំបាកៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬលើសពីនេះ
- មានសមត្ថភាពចាប់យកការងារថ្មី ឬតួនាទីថ្មី

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលបំណងអ្វីខ្លះ?

ក្នុងវិជ្ជាជីវៈខ្លះ ការអនុវត្តវិជ្ជាជីវៈជាប្រចាំគឺជាតម្រូវការតែម្តង ដើម្បីបញ្ជាក់ថាខ្លួនមានសមត្ថភាពលើការទទួលខុសត្រូវរបស់ខ្លួន។
ជាឧទាហរណ៍ ពេទ្យធ្មេញនៅអង់គ្លេសតាមច្បាប់ គឺចាំបាច់ត្រូវរក្សាឱ្យបាននូវសមត្ថភាព និងចំណេះដឹងរបស់ខ្លួនពេញមួយជីវិតវិជ្ជាជីវៈតែម្តង មានន័យថាពួកគាត់ត្រូវចំណាយពេល ២៥០ ម៉ោង សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គាត់រៀងរាល់ ៥ ឆ្នាំម្តង ហើយជំនួយការរបស់គាត់ និងពេទ្យថែទាំធ្មេញគឺ ១៥០ ម៉ោង។

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគោលដៅអ្វីខ្លះ?

- ជាទូទៅ លទ្ធផលនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវបានប្រើប្រាស់ដើម្បី៖
  - វាយតម្លៃនិយោជិក ឬអ្នកហាត់ការ។
  - វាស់វែងការចូលរួម ការប្តេជ្ញាចិត្ត និងសមត្ថភាពរបស់និយោជិក
  - ភស្តុតាងដើម្បីអាចឱ្យពួកគាត់ផ្តល់នូវតួនាទី ការទទួលខុសត្រូវច្បាស់លាស់មួយ។

ក្នុងស្ថានភាពទាំង ៣ ខាងលើនេះ ទាមទារឱ្យមានក្របខណ្ឌ ឬប្រព័ន្ធត្រួតពិនិត្យការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ច្បាស់លាស់មួយដែលអាចឱ្យពួកគេបញ្ជាក់បានពីភាពប្រាកដប្រជានៃការអនុវត្តការងារ ដោយគោរពទៅតាមគោលការណ៍រួមក្នុងការតែងតាំង ការដំឡើងឋានៈជាដើម។ល។

# តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខុសពីការសិក្សារៀនសូត្រផ្សេងទៀតបែបណាខ្លះ?

- < ¸B ផ្តោតលើការអភិវឌ្ឍជំនាញផ្ទាល់ខ្លួនប្រចាំអាជីពរបស់ខ្លួន ការសិក្សារៀនសូត្រគឺផ្តោតលើចំណេះដឹងទូទៅ ការសិក្សាលើជំនាញផ្សេងទៀតជាដើម
- ការសិក្សារៀនសូត្រលើមុខជំនាញដែលជាមូលដ្ឋានគ្រឹះ < ¸B វិញសំដៅដល់ខ្លួនឯងមានជំនាញមួយរួចទៅហើយ ហើយផ្តោតលើជំនាញមួយផ្សេងទៀត
- < ¸B ទាមទារឱ្យអនុវត្តទៅតាមផែនការរបស់ក្រសួងដែលត្រូវមានប្រាក់កម្រៃ ជំនាញសម្រាប់ការបំពេញការងារ ការសិក្សារៀនសូត្រគឺជាការបោះទុនសម្រាប់ខ្លួនឯង និងផ្តោតលើការស្រាវជ្រាវតែមួយគត់
- < ¸B ខុសគ្នាត្រង់ < ¸B គឺផ្តោតលើជំនាញណាមួយដែលពាក់ព័ន្ធនឹងការងាររបស់យើង

# តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខុសពីការសិក្សារៀនសូត្រផ្សេងទៀតបែបណាខ្លះ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខុសពីការសិក្សារៀនសូត្រផ្សេងទៀតបែបណាខ្លះ?

តើមានការយល់ច្រឡំដែរឬទេរវាងពាក្យទាំង ៣ នេះ៖ ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ?

- ការអប់រំ៖ ការណែនាំ ឬការបណ្តុះបណ្តាលផ្តែកសតិបញ្ញា និងសីលធម៌ដែលមានលក្ខណៈជាប្រព័ន្ធរៀបចំឡើងដើម្បីផ្តល់ដល់អ្នកចូលរួមនូវការយល់ដឹងទូលំទូលាយ និង/ឬ ស៊ីជម្រៅលើប្រធានបទដែលការបណ្តុះបណ្តាលនោះផ្តោត។ ការអប់រំផ្សារភ្ជាប់ជាទូទៅជាមួយនឹងកុមារ និងយុវជន។
- ការបណ្តុះបណ្តាល៖ ការផ្ទេរចំណេះដឹង និងសមត្ថភាពដែលអនុញ្ញាតឱ្យអ្នកទទួលអាចធ្វើការងារសម្រេចបានជាលទ្ធផល។ ការបណ្តុះបណ្តាលច្រើនតែផ្តោតលើសមត្ថភាពវិជ្ជាជីវៈ និងការយល់ដឹងជាក់លាក់លើប្រធានបទអ្វីមួយជានាបានថាអាចអនុវត្តបានក្នុងជីវិតការងារ។

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខុសពីការសិក្សារៀនសូត្រផ្សេងទៀតបែបណាខ្លះ?

ក្នុងន័យអប់រំ ការអប់រំគឺជាកម្មវិធីស៊ីជម្រៅមួយនៃការសិក្សារៀនសូត្រដែលរួមមានមួយផ្នែកធំទៅលើទ្រឹស្តី ការគិតពិចារណា និងការជជែកពិភាក្សា ហើយពេលខ្លះក៏មានការអនុវត្តផ្ទាល់ ឬដោយប្រយោល។

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំខុសពីការសិក្សារៀនសូត្រផ្សេងទៀតបែបណាខ្លះ?

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ អាចចាត់ទុកថាជាការអប់រំបន្ថែម និងការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងដែលបន្ថែមលើការអប់រំ និងការបណ្តុះបណ្តាល។

ការសិក្សាពេញមួយជីវិត




## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?

មាន ៤៖

- ផែនការដែលរួមមានសេវាកម្ម និងកិច្ចការតម្រូវផ្ដល់ដោយអង្គវិជ្ជាជីវៈណាមួយ។ វាជាកិច្ចការតម្រូវ ដែលត្រូវអនុវត្តដោយអង្គការងារណាមួយ អាចជាប្រចាំខែ ប្រចាំត្រីមាស ឆមាស ឆ្នាំ ជាដើម
- ផែនការដាក់ចេញដោយនិយោជកដែលតម្រូវឱ្យនិយោជិកទាំងអស់ចូលរួមដោយខានមិនបានដើម្បីធានាបាននូវសកម្មភាពការងារប្រចាំថ្ងៃរបស់ខ្លួន
- កម្មវិធីដែលតម្រូវឱ្យអ្នកវិជ្ជាជីវៈទាំងអស់ចូលរួមស្របតាមច្បាប់ដែលមានចែងក្នុងអង្គភាព
- ការរៀនសូត្រដែលមិនមានលក្ខណៈជារចនាសម្ព័ន្ធ និងក្រៅផ្លូវការដែលបុគ្គលម្នាក់អាចចូលរួមបានទៅតាមលទ្ធភាពរបស់គេ

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?




## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?



## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?




## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?



## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?

ប្រព័ន្ធចាំបាច់ដែលត្រូវរៀបចំសម្រាប់ជំរុញ CPD៖

- យន្តការចុះឈ្មោះ
- សៀវភៅណែនាំប្រតិបត្តិ
- កម្មវិធីណែនាំ តម្រង់ទិស

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមាននីតិវិធីបែបណាខ្លះ?

- CPD ជាទម្រង់នៃការសិក្សារៀនសូត្រផ្អែកជាសំខាន់លើទឹកចិត្តរបស់បុគ្គល។
- ការធ្វើ CPD គឺធ្វើដោយស្ម័គ្រចិត្ត ចេញពីចិត្តរបសបុគ្គល ប្រសិនបើមានការបង្ខិតបង្ខំ នោះនឹងមានផលវិបាកអវិជ្ជមាន និងជាការខ្ជះខ្ជាយទាំងពេលវេលា និងថវិកា។
- អាចមាន ឬមិនមានវិញ្ញាបនបត្រ ឬសញ្ញាបត្រ
- អាចមានការប្រឡង ឬមិនមានការប្រឡង
- អ្នកសិក្សាអាចធ្វើការវិភាគពីខ្លឹមសារពាក់ព័ន្ធនឹងកិច្ចការរបស់ខ្លួន ឬពាក់ព័ន្ធនឹងចំណង់ចំណូលចិត្តរបស់ខ្លួន

តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

ក្នុងក្របខណ្ឌការងាររបស់អង្គគ្រូបង្រៀន CPD គឺជាតម្រូវការ។ ក្រសួងបានចេញ







## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

បើទោះបីជាមានមតិខ្លះថា CPD នេះមិនសូវមានប្រយោជន៍ ដោយលើកឡើងថា ជាការងារដែលស៊ីពេលច្រើន អ្នកចូលរួមមិនសូវជាចាប់បាន ដោយសារកត្តាអាយុ កត្តាចំណេះដឹងមូលដ្ឋានជាដើមក៏ដោយចុះ ខាងក្រោមនេះ ជាគុណប្រយោជន៍ដែលយើងអាចមើលឃើញពីការអនុវត្ត CPD៖

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

- អាចកំណត់ភាពខ្លាំង ភាពខ្សោយ និងផ្នែកដែលអាចជួយកែលម្អសមត្ថភាពរបស់បុគ្គល
- តាមដាន និងគ្រប់គ្រងការកែប្រែបច្ចេកវិទ្យា សង្គម និង/ឬគោលនយោបាយ
- អភិវឌ្ឍជំនឿចិត្តលើខ្លួនឯង
- ពង្រឹងភាពជឿទុកចិត្តខ្លួនឯងក្នុងការទទួលខុសត្រូវរបស់ខ្លួន
- មានសមត្ថភាពក្នុងការសម្រេចបានគោលបំណងការងាររបស់ខ្លួនតាមរយៈផែនការអភិវឌ្ឍន៍សមត្ថភាព
- មានសមត្ថភាពក្នុងការឆ្លើយតបទៅតាមការផ្លាស់ប្តូររបស់សង្គម និងធ្វើបច្ចុប្បន្នកម្មជាប្រចាំសមត្ថភាព និងបទពិសោធន៍ទៅតាមតម្រូវការរបស់ការងារ

## តើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានគុណប្រយោជន៍អ្វីខ្លះ?

- មានឱកាសក្នុងការពិចារណាលើការសិក្សារៀនសូត្រ ការកំណត់ចំណុចខ្សោយ និងតម្រូវការរបស់ខ្លួនដើម្បីធានាបានលទ្ធផលការងារល្អប្រសើរ
- មានឱកាសក្នុងការទទួលបានការដំឡើងឋានៈ និងការឡើងបៀវត្ស

# ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន

## និយមន័យ

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានន័យថាជាដំណើរការនៃការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ ចំណេះដឹង និងជំនាញដោយឯករាជ្យ ដោយការចូលរួម ផ្អែកឬមិនផ្អែកលើការសិក្សារៀនសូត្រជាលក្ខណៈអន្តរសកម្ម
- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាដំណើរការដែលមនុស្សមានវិជ្ជាជីវៈ និងលក្ខណៈវិជ្ជាជីវៈអាចចាត់ថាត្រូវបានពង្រឹង ត្រូវបានធ្វើបច្ចុប្បន្នកម្ម ត្រូវបានលើកកម្ពស់។

## និយមន័យ «ត»

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគឺជាដំណើរការដែលគ្រូបង្រៀនអភិវឌ្ឍខ្លួនឯងក្រោយការចូលរួមការសិក្សាពេញមួយជីវិតទាំងក្នុង និងក្រៅផ្លូវការ និងទាំងតាមរយៈគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្ត ទាំងតាមរយៈកម្មវិធីដែលបានគ្រោង និងរៀបចំដោយអាជ្ញាធរ Bolitho and Padwad, 2013
- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគឺជាដំណើរការដែលបន្តពីការបណ្តុះបណ្តាលដំបូងទៅកេសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលកើតមានឡើងក្នុងជីវិតការងាររបស់បុគ្គល Hazarika, Nizara, 2011

## និយមន័យ «ត»

- គឺជាដំណើរការនៃការរៀបចំផែនការ ការអភិវឌ្ឍជាប្រចារបស់បុគ្គលម្នាក់តាមរយៈការងាររបស់គេ។ ដំណើរការនេះអនុវត្តបានសម្រាប់គ្រប់បុគ្គលិកទាំងអស់ តាមរយៈវគ្គសិក្សា ស្វ័យសិក្សា វគ្គផ្សេងៗទាំងក្រៅ និងផ្លូវការដើម្បីភាពរីកចម្រើនសតិបញ្ញាបុគ្គលខ្លួនឯង ក៏ដូចជាអង្គភាពដែលពួកគេបម្រើការ។

# សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅក្នុងបរិបទយើងនេះ គឺយើងនឹងផ្តោតជាសំខាន់លើវិស័យអប់រំដែលៈ
  - បុគ្គលិកអប់រំម្នាក់ៗត្រូវការដើម្បីកែលម្អវិជ្ជាជីវៈ ការទទួលខុសត្រូវរបស់ខ្លួន នោះមិនមែនមានន័យថាការងាររបស់គាត់មិនល្អនោះទេ តែគឺដើម្បីធ្វើឱ្យការងាររបស់ខ្លួនកាត់តែល្អ កាន់តែរីកចម្រើន កាន់តែមានភាពទាក់ទាញ Dylan William
  - ត្រូវចាំថា គ្រូបង្រៀនមិនអាចបង្រៀនបាននោះទេ លើកលែងតែគាត់នៅតែបន្តការសិក្សារៀនសូត្រដោយខ្លួនឯងជាប់ជាប្រចាំ Rabindranath Tagor

# សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ «ត»

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅក្នុងបរិបទយើងនេះ គឺយើងនឹងផ្តោតជាសំខាន់លើវិស័យអប់រំដែលៈ
  - កែលម្អផ្នែកបញ្ញា បុគ្គលិកលក្ខណៈ និងការជឿទុកចិត្តលើខ្លួនឯង
  - បើកគំនិតទទួលយកការងារថ្មី និងឱកាសថ្មីសម្រាប់ខ្លួនឯង
  - កែលម្អសមត្ថភាពក្នុងការសិក្សារៀនសូត្រ
  - ជំរុញការសិក្សារៀនសូត្រដោយឯករាជ្យ
  - បង្ហាញចេញនូវមហិច្ឆតា និងការប្តេជ្ញាចិត្តក្នុងការកែលម្អវិជ្ជាជីវៈ

## គុណប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- មានសមត្ថភាពបច្ចុប្បន្នភាពជាមួយនឹងចំណេះដឹង ចំណេះធ្វើថ្មីៗ និងរៀនសូត្របន្ថែមនូវជំនាញថ្មីៗ
- កែលម្អគុណផលការងាររបស់ខ្លួន
- ជំរុញការជឿទុកចិត្តលើខ្លួនឯង
- ពង្រឹងកិត្តិនាម និងកិត្តិសព្ទវិជ្ជាជីវៈ
- ទទួលបានភស្តុតាងថ្មីៗពាក់ព័ន្ធវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តរបស់ខ្លួន

## គុណប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ «ត»

- មានសមត្ថភាពបច្ចុប្បន្នភាពជាមួយនឹងចំណេះដឹង ចំណេះធ្វើថ្មីៗ និងរៀនសូត្របន្ថែមនូវជំនាញថ្មីៗ
- កែលម្អគុណផលការងាររបស់ខ្លួន
- ជំរុញការជឿទុកចិត្តលើខ្លួនឯង
- ពង្រឹងកិត្តិនាម និងកិត្តិសព្ទវិជ្ជាជីវៈ
- ទទួលបានភស្តុតាងថ្មីៗពាក់ព័ន្ធវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តរបស់ខ្លួន

# សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

# សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

- ជួយបុគ្គលិកអប់រំក្នុងការរក្សាបាននូវចំណេះដឹងវិជ្ជាជីវៈ និងសមត្ថភាពមានបច្ចុប្បន្នភាព។ ត្រូវចាំថាមនុស្សជំនាន់ថ្មីមានវិធីសាស្ត្រក្នុងការសិក្សាខុសពីមនុស្សជំនាន់មុន។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំអាចជួយដល់បុគ្គលិកអប់រំក្នុងការរៀនសូត្របច្ចេកទេសថ្មីៗសម្រាប់ការបង្រៀនសិស្សបច្ចុប្បន្ន។
- បុគ្គលិកអប់រំដែលមានអតីតភាពក្នុងការងារជាច្រើនឆ្នាំ ច្រើនតែមានការស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូររបៀបបង្រៀនរបស់ខ្លួន ក្នុងន័យនេះ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនឹងធ្វើឱ្យពួកគាត់អាចរក្សាបាននូវចំណេះដឹង ចំណេះធ្វើដែលមានបច្ចុប្បន្នភាពក្នុងវិស័យអប់រំ។

# សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ «ត»

- លើកទឹកចិត្តក្នុងការធ្វើបម្លាស់ប្តូរចំណេះដឹងរវាងគ្នានឹងគ្នា
  - ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើកទឹកចិត្តបុគ្គលិកអប់រំក្នុងការផ្លាស់ប្តូរចំណេះដឹង និងគំនិតរវាងគ្នានឹងគ្នានៅក្នុងសាលារៀន។ ក្នុងន័យនេះ បុគ្គលិកអប់រំដែលមានអតីតភាពច្រើនឆ្នាំអាចដើរតួនាទីជាអ្នកតាមជួយ Mentor សម្រាប់គ្រូថ្មី
- កែលម្អកិច្ចទំនាក់ទំនងរវាងសាលារៀន និងសាលារៀន
  - ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំធ្វើឱ្យគ្រូបង្រៀនជួបជាមួយសហការីមកពីសាលាផ្សេង។ ការធ្វើបែបនេះក៏នឹងបង្កើនការចែករំលែកចំណេះដឹង ព្រមទាំងការរៀនសូត្រនូវបច្ចេកទេសថ្មីៗពីគ្នាទៅវិញទៅមក។ ប្រការនេះធ្វើឱ្យមានការកែលម្អគុណភាពអប់រំតាមរយៈការចែករំលែកចំណេះដឹង។

## សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ «ត»

- ទម្រង់នៃការអភិវឌ្ឍនេះត្រូវមានភាពបត់បែន
  - គ្រូបង្រៀនអាចរៀនតាមអនឡាញក្នុងបរិបទថ្មីដោយមិនចាំបាច់ទៅរៀននៅក្នុងថ្នាក់រៀនដោយផ្ទាល់។ នាពេលបច្ចុប្បន្ននេះមានទម្រង់បង្រៀនតាមអនឡាញនេះច្រើនដែលអនុញ្ញាតឱ្យគ្រូបង្រៀនបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនកាន់តែងាយស្រួល
- ទទួលបានឱកាសការងារកាន់តែប្រសើរ
  - ការអភិវឌ្ឍនេះជួយឱ្យបុគ្គលិកអប់រំទទួលបាននូវឋានៈវិជ្ជាជីវៈ ហើយខ្លឹមសារមេរៀននៃការអភិវឌ្ឍនេះដែលមានលក្ខណៈផ្សារភ្ជាប់ជាមួយនឹងការងារវិជ្ជាជីវៈគ្រូបង្រៀន នឹងធ្វើឱ្យគ្រូបង្រៀនកាន់តែមានភាពងាយស្រួលក្នុងការអនុវត្តកិច្ចការរបស់ខ្លួន

## សារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ «ត»

- វាជាភស្តុតាងបញ្ជាក់ពីសមត្ថភាព
  - បំពេញបានវគ្គអភិវឌ្ឍនេះមួយផ្តល់ជាភស្តុតាងនូវសមត្ថភាពរបស់ខ្លួនមួយ។ មានន័យថា វាបានជួយដល់បុគ្គលិកអប់រំម្នាក់ឱ្យមានសមត្ថភាពដាច់ដោយឡែកធៀបនឹងបុគ្គលិកអប់រំផ្សេងទៀត។ អ្នកដែលបន្តរៀននឹងមានសមត្ថភាពលើសអ្នកដែលមិនបន្តរៀន
  - ការអភិវឌ្ឍនេះផ្តល់បន្ថែមដល់ជំនាញដែលមានស្រាប់។ បុគ្គលិកអប់រំដែលបន្តការអភិវឌ្ឍនេះកាន់តែមានជំនឿចិត្តលើខ្លួនឯងក្នុងការបង្រៀន ហើយអាចឆ្លើយតបបានទៅតាមតម្រូវការរបស់សិស្ស គណៈគ្រប់គ្រង និងមាតាបិតា/សហគមន៍

# ហេតុអ្វីបានជាការអភិវឌ្ឍនេះមានសារៈសំខាន់?

- ការផ្លាស់ប្ដូរត្រូវមានជាប់ជាប្រចាំ ដែលប្រការនេះយើងអាចសង្កេតឃើញនៅក្នុងលោកដែលយើងរស់នៅស្រាប់ទៅហើយ ក្នុងន័យនេះវាពិតជាចាំបាច់ណាស់ក្នុងការរក្សាឱ្យបានវឌ្ឍនភាពក្នុងកិច្ចការវិជ្ជាជីវៈរបស់យើង
- មធ្យោបាយដែលល្អបំផុតដើម្បីធ្វើកិច្ចការនេះ គឺការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីយើងអាចនៅពីលើការងារបាន
- ការរៀនសូត្រជាប្រចាំស្ដែងចេញជាលទ្ធផលល្អក្នុងការអនុវត្តការងារ ក្នុងន័យនេះប្រសិនបើយើងចង់សម្រេចបានលទ្ធផលកាន់តែល្អក្នុងការងារ ការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគឺជាជម្រើសដ៏ល្អបំផុត។

# ប្រភេទ/ទម្រង់នៃ
# ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

# ប្រភេទ/ទម្រង់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## ប្រភេទ/ទម្រង់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្លូវការ៖ ជាទម្រង់បែបសកម្ម និងបែបរចនាសម្ព័ន្ធ ដោយមានគោលបំណងនិងការកំណត់ផលសម្រេចច្បាស់លាស់។ សកម្មភាពខ្លះក្នុងទម្រង់នេះមានដូចជា៖
  - កម្មវិធីបណ្តុះបណ្តាលអូហ្វឡាញ ឬអនឡាន
  - ការសិក្សាតាមបែបសិក្ខាសាលា និងសន្និសីទ
  - សិក្ខាសាលា(អនុវត្តន៍) និងព្រឹត្តិការណ៍ផ្សេងៗ
  - ជាទម្រង់នៃការបង្រៀនដូចថ្នាក់រៀន

## ប្រភេទ/ទម្រង់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ «គ»

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមិនផ្លូវការ៖ ជាទម្រង់បែបស្វ័យសិក្សារៀនសូត្រដែលត្រូវផ្សារភ្ជាប់ ឬពាក់ព័ន្ធនឹងតួនាទីវិជ្ជាជីវៈរបស់បុគ្គល ដោយបុគ្គលធ្វើការអភិវឌ្ឍសមត្ថភាពចំណេះដឹង ចំណេះធ្វើរបស់ខ្លួនទៅតាមការជ្រើសរើស តាមការចូលចិត្ត ដោយមិនមានកម្មវិធីរចនាសម្ព័ន្ធអ្វីនោះឡើយ។ ទម្រង់នេះមានដូចជា៖
  - រៀនពីការងារដែលខ្លួនកំពុងធ្វើ
  - រៀនតាមរយៈសង្កេត តាមដានអ្នកដទៃ
  - ចូលរួមរៀននៅក្នុងសិក្ខាសាលាមិនផ្លូវការ ឬពីព្រឹត្តិការណ៍ផ្សេងៗដែលផ្តោតលើការផ្លាស់ប្តូរចំណេះដឹង
  - រៀនជាលក្ខណៈឯកជន

## វដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- ការអភិវឌ្ឍនេះបង្ហាញថាការអភិវឌ្ឍវិជ្ជាជីវៈគឺមាគ៌ាដ៏ប្រសើរបំផុតក្នុងការចូលរួមអភិវឌ្ឍគុណភាពសេវាកម្មដែលត្រូវផ្តល់ទៅដល់សិស្ស។ ដំណើរការនេះការអភិវឌ្ឍនេះត្រូវគិតជាដំបូងដល់សមាសភាពដូចខាងក្រោម៖
  - កំណត់តម្រូវការក្នុងការអភិវឌ្ឍតាមរយៈការរៀបចំផែនការ
  - អនុវត្តសកម្មភាពសិក្សារៀនសូត្រ
  - ពិចារណាលើអ្វីដែលខ្លួនបានសិក្សារៀនសូត្រ
  - អនុវត្តអ្វីដែលបានសិក្សារៀនសូត្រ
  - ចែករំលែកចំណេះដឹង បទពិសោធន៍ដែលបានមកពីការសិក្សារៀនសូត្រ និងអនុវត្ត

# វដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ




# ១. កំណត់តម្រូវការ

- មានវិធីជាច្រើនដើម្បីកំណត់តម្រូវការក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន៖
  - ឧទាហរណ៍ លោកអ្នកអាចរៀបចំធ្វើការវិភាគលើជំនាញដែលខ្លួនមានតាមរយៈការធ្វើស្វ័យវាយតម្លៃ និងការវាយតម្លៃ។ តាមរយៈការធ្វើបែបនេះ លោកអ្នកអាចដឹងពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួនពីខ្លួនឯង និងពីអ្នកនៅជុំវិញខ្លួន។
  - បានព័ត៌មានទាំងនោះហើយ លោកអ្នកអាចកំណត់ចំណុចណាមួយដែលលោកអ្នកមានការចាប់អារម្មណ៍ខ្លាំងជាងគេ និងចង់អភិវឌ្ឍផ្នែកនោះខ្លាំងជាងគេ
  - នៅពេលដែលលោកអ្នកកំណត់បានច្បាស់លាស់ហើយ លោកអ្នកត្រូវរៀបចំផែនការសម្រាប់អនុវត្តសកម្មភាពដើម្បីសម្រេចបាននូវអ្វីដែលលោកអ្នកកំណត់។

## ២. រៀបចំផែនការ និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាព

- សកម្មភាពអភិវឌ្ឍសមត្ថភាពមានដូចជា៖
  - ផ្លូវការ ជាទម្រង់សេវាបណ្តុះបណ្តាលមួយដែលផ្តល់ដោយអ្នកខាងក្រៅ ហើយអាចត្រូវបង់ថ្លៃ ឬមិនបង់ថ្លៃ ក្នុងន័យនេះដើម្បីកាត់បន្ថយការចំណាយ ឬទទួលបានការមិនគិតថ្លៃ លោកអ្នកអាចរៀនតាមអនឡាញ
  - មិនផ្លូវការ រួមមានការរៀនដោយខ្លួនឯង ការបង្រៀនតាមវីដេអូ ការបង្ហឹក ឬការអានលើប្រធានបទអ្វីមួយដែលលោកអ្នកចាប់អារម្មណ៍ជាដើម។

## ៣. ពិចារណាពីអ្វីដែលបានរៀន

- ពិចារណាលើអ្វីដែលបានសិក្សារៀនសូត្រគឺជាអ្វីដែលត្រូវធ្វើចាំបាច់បំផុតសម្រាប់អ្នកសិក្សា ជាពិសេសសម្រាប់លោក លោកស្រីដែលជាគ្រូបង្រៀន។ ត្រូវចាំថាការសិក្សាគឺមិនមែនត្រឹមតែចេញពីអ្វីដែលអ្នកមានបំណងចង់បាននោះទេ តែត្រូវពិនិត្យមើលថាតើអ្វីដែលបានទទួលពីការសិក្សារៀនសូត្រ លោកអ្នកអាចយកវាទៅធ្វើអ្វីបានខ្លះ និងយល់ដឹងបានដល់កម្រិតណាជាដើម។
- ទោះជាក្នុងករណីផ្លូវការ ឬមិនផ្លូវការក៏ដោយចុះ សកម្មភាពដែលបានរំពឹងទុក គឺលោកអ្នកត្រូវកត់ត្រាសកម្មភាពទាំងនោះថាតើវាមានប្រយោជន៍សម្រាប់អ្នកកម្រិតណា នៅក្នុងគោលដៅណា ពេលណា ជាមួយអ្នកណា នៅកន្លែងណាជាដើម។ ក្នុងគ្រប់ករណីទាំងអស់ អ្វីដែលបានសិក្សារៀនសូត្រត្រូវយកមកគិត រួចយកទៅអនុវត្តនៅក្នុងក្របខណ្ឌការងាររបស់អ្នកដើម្បីរកភាពរីកចម្រើន។

# ៨. អនុវត្តអ្វីដែលបានសិក្សារៀនសូត្រ

- ទៅសិក្សារៀនសូត្រ ឬមើលវិដេអូរៀនសូត្រគឺគ្រាន់ជាចំណុចចាប់ផ្ដើមប៉ុណ្ណោះ។ អ្វីដែលត្រូវធ្វើ បន្ទាប់គឺការយកអ្វីដែលបានរៀននោះទៅអនុវត្តនៅក្នុងក្របខណ្ឌការងាររបស់ខ្លួន។ សមត្ថភាពខាងទ្រឹស្ដីដែលបានមកពីការសិក្សាគឺអាចបែងចែកជា ៤ ដំណាក់កាលដូចខាងក្រោម៖
  - ភាពមិនដឹងខ្លួនដោយអចេតនា៖ មិនដឹងពីអ្វីដែលមិនដឹង
  - ភាពមិនដឹងខ្លួនដោយចេតនា៖ ដឹងថាត្រូវអភិវឌ្ឍខ្លួនឯងចំណុចណា និងមើលអ្នកដ៏ទៃធ្វើវា តែនៅតែមិនអាចធ្វើវាដោយខ្លួនឯងជាមួយនឹងសមត្ថភាពដែលខ្លួនមាន
  - ដឹងពីសមត្ថភាពខ្លួន៖ មានសមត្ថភាពក្នុងការធ្វើអ្វីមួយដោយសមហេតុផលដែលយើងផ្ដោតអារម្មណ៍ធ្វើវា
  - ភាពមិនដឹងខ្លួនលើសមត្ថភាពរបស់ខ្លួន៖ មានសមត្ថភាពធ្វើអ្វីមួយដោយសភាវគតិ ដោយមិនត្រូវការផ្ដោតអារម្មណ៍លើការងារនោះ។

# ៨. អនុវត្តអ្វីដែលបានសិក្សារៀនសូត្រ«ត»

- នៅពេលអ្នកសម្រេចការបណ្ដុះបណ្ដាលអ្វីមួយ ឬវគ្គអភិវឌ្ឍសមត្ថភាពណាមួយ លោកអ្នកអាចនឹងនៅចន្លោះរវាងដឹងពីអសមត្ថភាពរបស់ខ្លួន និងដឹងពីសមត្ថភាពរបស់ខ្លួន គឺអាស្រ័យទៅលើសមត្ថភាពរបស់លោកអ្នកក្នុងការអនុវត្តកិច្ចការដោយផ្ទាល់
- ក្នុងន័យនេះ លោកអ្នកត្រូវការពេលវេលាដើម្បីអនុវត្តអ្វីដែលបានរៀនសូត្រ និងអនុវត្តនៅក្នុងពេលរៀន ដើម្បីឆ្ពោះទៅរកដំណាក់កាលថ្មីមួយទៀត គឺការមិនដឹងថាខ្លួនមានសមត្ថភាព

## ៨. ចែករំលែកអ្វីដែលអ្នកបានរៀនទៅអ្នកដទៃ

- យើងអាចបន្ថែមដំណាក់កាលទី ៥ នេះ ទៅក្នុងវដ្តនៃសមត្ថភាពដែលយើងអាចធ្វើបាន គឺមានន័យថាបង្រៀនអ្នកដទៃ។
- វាពិតណាហើយថាមានសមត្ថភាពក្នុងការប្រែក្លាយសមត្ថភាពរបស់ខ្លួនទៅជាមេរៀនសម្រាប់បង្រៀនអ្នកដទៃ ចែករំលែកអ្វីដែលខ្លួនបានសិក្សារៀនសូត្រ គឺជាអ្វីដែលសំខាន់បំផុតដើម្បីជឿជាក់ថាលោកអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអ្វីដែលខ្លួនមាន និងអាចផ្ទេរទៅអ្នកដទៃបាន

## ការរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ



**តម្រូវ**

គោលការណ៍ពីលើចុះក្រោម៖ តម្រូវការចេញមកពីអ្វីដែលជាគោលដៅ គោលបំណងរបស់គ្រឹះស្ថាន

**ចរចារ/សម្របសម្រួល**

តម្រូវការត្រូវបានបង្ហាញដោយបុគ្គលិកតាមរយៈគណៈគ្រប់គ្រង

## សកម្មភាព

- បង្កើតផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ខ្លួន

១៥ នាទី

## កត់ត្រាកិច្ចអភិវឌ្ឍរបស់ខ្លួន

- កត់ត្រាតម្រូវការអភិវឌ្ឍ និងគោលដៅរបស់ខ្លួន ព្រមទាំងធ្វើការវាយតម្លៃជាប់ជាប្រចាំនូវវឌ្ឍនភាពរបស់ខ្លួនធៀបនឹងតម្រូវការ និងគោលដៅនោះ
- កត់ត្រាខ្លឹមសារមេរៀននៅក្នុងវគ្គបណ្ដុះបណ្ដាលដែលបានចូលរួម ដោយភ្ជាប់ជាមួយនឹងវិញ្ញាបនបត្រ ឬអ្វីដែលបញ្ជាក់ពីគុណវុឌ្ឍិដែលបានទទួល។ រក្សាទុកកាលបរិច្ឆេទ អ្នកផ្ដល់ គោលបំណងរបស់វគ្គ និងការយល់ឃើញរបស់អ្នកពីអ្វីដែលអ្នកបានរៀនសូត្រក្នុងវគ្គទាំងនោះ
- ប្រសិនបើអ្នកមានអ្វីពាក់ព័ន្ធនឹងបញ្ហាប្រឈមអ្វីមួយ ឬក៏មានខុសឆ្គងណាមួយតាមរយៈការសិក្សារៀនសូត្រទាំងនោះ លោកអ្នកក៏ត្រូវកត់ត្រាលម្អិតពីបញ្ហាទាំងនោះ កត់ត្រាពីអ្វីដែលបានរៀន និងអ្វីដែលលោកអ្នកនឹងធ្វើដែលមានលក្ខណៈផ្ទុយពីអ្វីដែលបានរៀននោះ។

# គោលបំណងនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- ខាងក្រោមនេះជាគោលបំណងធំៗដែលអាចឃើញមាននៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន៖
  - ការអភិវឌ្ឍការប្រឹក្សាយោបល់ និងកម្មវិធីសិក្សា
  - ការធ្វើបច្ចុប្បន្នកម្មមុខវិជ្ជាឯកទេស
  - ការធ្វើបច្ចុប្បន្នកម្មលើផ្នែកសង្គម និងបញ្ហាក្នុងប្រព័ន្ធអប់រំ
  - កិច្ចសហប្រតិបត្តិការរវាងគ្រូបង្រៀន និងគ្រូបង្រៀន
  - ការប្រែក្លាយការអនុវត្តគរុកោសល្យដែលមានស្រាប់ទៅជាការបង្កើតកម្មវិធីគរុកោសល្យដែលធ្វើឱ្យបរិស្ថានសិក្សារបស់សិស្សកាន់តែមានភាពទាក់ទាញ

# ចំណុចគន្លឹះទាំង ១០ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ

1. ការអភិវឌ្ឍសកម្មភាពជាជំហាន
2. ការដាក់ចេញគោលដៅរយៈពេលវែង
3. ចំណេះដឹងបច្ចេកទេស
4. កត់ត្រាពេលវេលាប្រសើរបំផុត
5. វាយតម្លៃខ្លួនឯង
6. ប្រមើលមើលស្ថានការណ៍ និងកត់ចំណាំ
7. ត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្លាស់ប្តូរ
8. ធ្វើតារាងជំនាញរបស់ខ្លួន និងរបៀបប្រើប្រាស់ជំនាញទាំងនោះក្នុងការងារប្រចាំថ្ងៃ
9. ធ្វើការងារជាក្រុម
10. យកមេរៀនថ្មីមកសាកល្បងអនុវត្ត និងកត់ត្រា

## គន្លឹះសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ

វាជាការល្អដែលត្រូវមានសៀវភៅសម្រាប់កត់ត្រាការសិក្សារៀនសូត្រប្រចាំថ្ងៃ របៀបជាសៀវភៅកំណត់ហេតុ។ បង្កើតទម្លាប់ក្នុងការសរសេរពីអ្វីដែលកើតឡើងក្នុងការងារឱ្យបានយ៉ាងហោចណាស់ម្តងក្នុង១ សប្តាហ៍។ សម្រាប់ព្រឹត្តិការណ៍ ឬសកម្មភាពដែលកើតឡើងហើយដែលលោកអ្នកគិតថាមានប្រយោជន៍សម្រាប់ជីវិតការងារ ដោយត្រូវកត់ត្រាចំណុចដូចខាងក្រោម៖

1. ស្ថានការណ៍
2. អ្វីដែលអ្នកបានសិក្សាពីវា
3. អ្វីដែលអ្នកនឹងធ្វើវាខុសពីអ្វីដែលគេធ្វើដើម្បីសម្រេចបានលទ្ធផលល្អប្រសើរ

កំណត់ហេតុនេះអាចប្រើប្រាស់បានដើម្បីយល់ដឹងពីវឌ្ឍនៈភាពរបស់លោកអ្នកធៀបនឹងគោលបំណង ឬគោលដៅរួម

## គន្លឹះសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ «ត»

ជាប្រការល្អ ប្រសិនបើលោកអ្នកអាចពិភាក្សាពីវឌ្ឍនភាព និងការផ្លាស់ប្តូររបស់លោកអ្នកជាមួយសហការី។ ចែករំលែកបទពិសោធន៍ដែលលោកអ្នកបានសិក្សាស្វែងយល់ គឺជាឧបករណ៍ដ៏ល្អមួយដែលអាចជួយលោកអ្នកក្នុងការស្វែងរកចំណុចដែលត្រូវអភិវឌ្ឍ ឬក៏គំនិតនានាដើម្បីអភិវឌ្ឍសកម្មភាពប្រចាំថ្ងៃរបស់លោកអ្នកក្នុងនាមជាអ្នកអប់រំ

## គន្លឹះសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ «ត»

ឧទាហរណ៍ក្នុងការរៀបចំផែនការសម្រាប់អភិវឌ្ឍសមត្ថភាពរបស់ខ្លួន

មុនពេលអភិវឌ្ឍ

1. ចំណាយពេលវេលាដើម្បីមើលឡើងវិញនូវកម្មវិធី
2. ស្រាវជ្រាវប្រធានបទ ឬខ្លឹមសារនានាដែលមានប្រយោជន៍សម្រាប់ការអភិវឌ្ឍសមត្ថភាពខ្លួនឯង

អំឡុងពេល

រក្សាកំណត់ត្រាអ្វីដែលបានសិក្សា/ធ្វើសំយោគ ឬសង្ខេង/វាយតម្លៃ

ក្រោយពេល

ផ្សព្វផ្សាយ/ចែករំលែក/ប្រតិបត្តិ/អនុវត្ត

## តើអ្វីទៅជាការអភិវឌ្ឍបុគ្គលខ្លួនឯង?

ការអភិវឌ្ឍបុគ្គលខ្លួនឯងគឺជានីតិវិធី ឬដំណើរការរយៈពេលវែងក្នុងជីវិត។

ជាវិធីសម្រាប់មនុស្សក្នុងការវាយតម្លៃជំនាញ ឬគុណសម្បត្តិរបស់ខ្លួន ពិនិត្យមើលពីគោលដៅ គោលបំណងរបស់ខ្លួនក្នុងជីវិត និងដាក់ចេញគោលដៅដើម្បីសម្រេចឱ្យបានប្រសើរបំផុតនូវសក្តានុពលដែលខ្លួនមាន។

## ត្រូវចាំសម្ដីរបស់លោក Mullins, 2007 ដែលលើកឡើងថា « ការអភិវឌ្ឍខ្លួនឯងត្រូវតែចាប់ផ្តើមចេញពីខ្លួនឯង»

*"Self development has to be self–initiated"* (Mullins, 2007)



## វដ្តនៃការសិក្សារៀនសូត្រ តាម Kolb 1984



# ផលប្រយោជន៍សម្រាប់លោកអ្នក...

មនុស្សដែលប្រសើរបំផុតក្នុងការងារ ឬកិច្ចការពាណិជ្ជកម្មសុទ្ធតែជាអ្នកស្វែងយល់សិក្សារៀនសូត្រ ចេះសួរខ្លួនឯង ចេះដោះស្រាយបញ្ហា និងប្រតិបត្តិក្នុងកិច្ចការថ្មីជាប្រចាំ

មនុស្សបែបនេះមិនមានសេចក្តីបារម្ភពីថាតើគេត្រូវបានប្រើប្រាស់នោះទេ។ មនុស្សបែបនេះជាមនុស្សដែលអង្គភាពនានាត្រូវការបំផុតដើម្បីជួយឱ្យមានការរីកចម្រើននៅក្នុងអង្គភាពដែលគេបម្រើការងារ

មនុស្សប្រភេទនេះក្លាយជាអ្នកដឹកនាំ អ្នកបង្វឹងណែនាំអ្នកនៅជុំវិញខ្លួនគេទាំងក្នុងនិងក្រៅផ្លូវការ (Farren, C. ‘Mastery: The Critical Advantage’, in Chowdhury, S. ‘Management 21C, Financial Times Prentice Hall (2000), p98)

# កំណត់ប្រធានបទសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់លោកអ្នក និងកំណត់ផលប្រយោជន៍ដែលលោកអ្នក និងអង្គភាពអាចទទួលបាន

| លោកអ្នក | អង្គភាព |
|---|---|
| | |

# គោលការណ៍នៃការប្រតិបត្តិ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីព

## ចក្ខុវិស័យ

ពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីគាំទ្រគោលដៅអភិវឌ្ឍដោយចីរភាព និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ «**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**»

## គំរូជោគជ័យ

- ពន្លឿនកំណែទម្រង់អភិបាលកិច្ចក្នុងគ្រឹះស្ថានសិក្សា
  - ដំណាក់កាលដំបូង ផ្តល់ប្រព័ន្ធ និងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិផ្អែកលើក្រេឌីត ដោយសម្រេចបានសមិទ្ធផលដូចខាងក្រោម៖
    - គ្រូបង្រៀន ២៤៣០ នាក់ បានទទួលជោគជ័យក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន
    - គណៈគ្រប់គ្រងសាលារៀនចំនួន ៤៥៤ នាក់ បានបញ្ចប់ការសិក្សានៅក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន
    - មន្ត្រីថ្នាក់កណ្តាល ១៥២ នាក់បានបញ្ចប់ការសិក្សានៅក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន

| គន្លងអាជីព | អ្នកមានវិជ្ជាជីវៈដំបូង | អ្នកឯកទេស | អ្នកឯកទេសជាន់ខ្ពស់ |
|---|---|---|---|
| | 2021-2025 | 2021-2025 | 2021-2025 |
| ថ្នាក់ជាតិ | 25 | 17 | 4 |
| ថ្នាក់រាជធានី ខេត្ត | 7000 | 75 | 0 |
| សរុប | 7025 | 92 | 4 |

## សហគមន៍សាលារៀនជំរុញដំណើរការការអភិវឌ្ឍសាលារៀនដោយប្រើប្រាស់នីតិវិធីប្រកបដោយចីរភាព

រង្វាន់ដល់គ្រូបង្រៀន
ដល់គណៈគ្រប់គ្រង
សាលារៀន

សិស្សមានជំនាញឆ្លើយតប និងមានចំណូល/កម្មវិធីសន្សំប្រាក់ និងចូលរៀននៅឧត្តមសិក្សា


ការងារ និងការគាំទ្រកំណើន


ប្រការដែលសហគមន៍ជាម្ចាស់សាលារៀនធ្វើឱ្យមានការកែលម្អស្វ័យតាព
លើរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីលទ្ធផលកាន់តែប្រសើរឡើង
ប្រភពចំណូល៖ មាតាបិតាចូលរិភាគទាន ការអនុវត្តបំណិនរកប្រាក់ចំណូល ការធ្វើអំណោយរបស់ដៃគូ ការរៀបចំកម្មវិធីជានាវ៉ាប់វង សេវាកម្មផ្សេងៗរបស់សាលារៀន
គ្រប់គ្រងគ្រូបង្រៀន៖ ធ្វើសកម្មភាពក្នុងសាលារៀន ១០ ម៉ោង ក្នុង ១ ថ្ងៃ
រៀបចំការបង្រៀន ភាសាបរទេស កុំព្យូទ័រ ថ្នាក់ជំនាញបច្ចេកវិទ្យា និងបំពាក់ឧបករណ៍ចាំបាច់នានា
គណៈគ្រប់គ្រងសាលារៀន៖ កម្មវិធីប្រតិបត្តិសមស្របមន្ត្រីថ្នាក់កណ្តាល និងថ្នាក់ខេត្ត៖ ការគ្រប់គ្រង និងជំនួយផ្នែកបច្ចេកទេស
សិស្សមានជំនាញ និងមានចំណូលព្រមទាំងបន្តចូលរៀននៅឧត្តមសិក្សា

## គោលដៅគុណផល

| ឈ្មោះស្តង់ដាសាលារៀនគំរូ | អ្នកទទួលខុសត្រូវ |
|---|---|
| ស្តង់ដាទី 1៖ លទ្ធផលសិក្សារបស់សិស្ស ( ទិន្នន័យយែនឌ័រ គ្រប់សូចនាករ ) | គ្រូបង្រៀន/គណៈគ្រប់គ្រងសាលារៀន |
| ស្តង់ដាទី 2៖ ការបង្រៀន និងរៀន | គ្រូបង្រៀន/គណៈគ្រប់គ្រងសាលារៀន |
| ស្តង់ដាទី 3៖ ការចូលរួមរបស់សហគមន៍ | គណៈគ្រប់គ្រងសាលារៀន |
| ស្តង់ដាទី 4៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | គណៈគ្រប់គ្រងសាលារៀន |
| ស្តង់ដាទី 5៖ គណនេយ្យភាពសាលារៀន | គណៈគ្រប់គ្រងសាលារៀន |

## គោលដៅគុណផល

# ការគ្រប់គ្រងផ្អែកលើលទ្ធផល

- រៀបចំការវាយតម្លៃសិស្ស (នៅដើមឆ្នាំសិក្សា)
- រៀបចំផែនការអភិវឌ្ឍសាលារៀនជាមួយគ្រប់ភាគីពាក់ព័ន្ធ
- រៀបចំផែនការអភិវឌ្ឍថ្នាក់រៀនជាមួយនឹងសិស្ស និងមាតាបិតាសិស្ស
- រៀបចំកិច្ចព្រមព្រៀងលទ្ធផលជាមួយគ្រូបង្រៀន សិស្ស គណៈគ្រប់គ្រង

# សំណួរត្រិះរិះ

- រៀបចំតារាងវិភាគសមត្ថភាពរបស់បុគ្គលិកអប់រំក្នុងគ្រឹះស្ថានសិក្សារបស់អ្នក ដោយប្រើប្រាស់តារាង S=Strengths, W=Weakness, O=Opportunities, T=Threat (SWOT)
- ប្រើប្រាស់លទ្ធផលចេញពីតារាងវិភាគនេះដើម្បីរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនក្នុងឆ្នាំសិក្សា ២០២៤-២០២៥

# តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

a. គោលដៅ និងជម្រើសគោលនយោបាយរបស់ជាតិជាគោលសម្រាប់រៀបចំផ្លូវ និងជម្រើសសកម្មភាពរបស់គ្រឹះស្ថានសិក្សា

- ចក្ខុវិស័យរបស់ជាតិ «២០៣០ ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់» និងជម្រើសរបស់ជាតិ «កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព» ត្រូវបានប្រើប្រាស់ និងចាំបាច់ត្រូវអនុវត្តតាមដើម្បីចំណេញពេលវេលាក្នុងការសម្រេចបានចក្ខុវិស័យនេះក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំ។

b. ពន្លឿនកំណែទម្រង់ក្នុងអភិបាលកិច្ចគ្រឹះស្ថានសិក្សាដើម្បីកែលម្អប្រសិទ្ធភាពការងារ និងគុណផល

- ដើម្បីពន្លឿនកំណែទម្រង់គ្រឹះស្ថានសិក្សា ការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រសាលារៀនគំរូ ដែលផ្តោតលើភាពជាអ្នកដឹកនាំបែបចែករំលែក ការកសាងសមត្ថភាពមនុស្ស ការកែលម្អភាពស្អាតស្អំ និងតម្លាភាព ការគ្រប់គ្រងគុណផល និងការផ្តល់រង្វាន់លើកទឹកចិត្ត កិច្ចសន្យាសាធារណៈលើលទ្ធផលដើម្បីកសាងគណនេយ្យភាព និងជំរុញភាពជាម្ចាស់។

# តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

c. កសាងមូលធនមនុស្សផ្អែកលើសមត្ថភាពបុគ្គល ផ្លាស់ប្តូរផ្នត់គំនិត កំណែទម្រង់ប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលបន្ត

- បទពិសោធន៍គម្រោង SEIP គឺបានធ្វើឱ្យការអភិវឌ្ឍសមត្ថភាពមនុស្សមានដំណើរការដោយប្រើប្រាស់ និងយកគំរូពីបទពិសោធន៍សកលលោក ឧ. សកលភាវូនីយកម្មកម្មវិធីបណ្តុះបណ្តាលបន្ត។ កម្មវិធី និងប្រព័ន្ធបណ្តុះបណ្តាលបន្តបានធ្វើឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនទទួលបានការយល់ដឹងថ្មី ផ្លាស់ប្តូរទម្លាប់ ទទួលយកអាកប្បកិរិយាថ្មី និងទទួលបានចំណេះដឹងថ្មីៗដើម្បីធ្វើឱ្យប្រព័ន្ធសាលារៀនមានភាពប្រទាក់ក្រឡាគ្នា និងមានដំណើរការដោយរលូន។

## តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

- លើសពីនោះទៅទៀត ផែនការសកម្មភាពរយៈពេលមធ្យមនេះគឺជាឧបករណ៍គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈ២០២៤ ដល់ ២០២៨ របស់រាជរដ្ឋាភិបាល។ ក្រុមការងារគម្រោងសម្របសម្រួលក្នុងការអនុវត្តផែនការសកម្មភាពរយៈពេលមធ្យមដើម្បីឱ្យសាលារៀនក្នុងគម្រោងនៅក្នុងទាំង ៣ អនុវិស័យសម្រេចបានស្តង់ដាសាលារៀនគំរូ
- សៀវភៅណែនាំប្រតិបត្តិស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពសម្រាប់មន្ត្រីអប់រំត្រូវបានរៀបចំដោយផ្អែកលើឧត្តមានុវត្ត និងភាពជោគជ័យនៃការអនុវត្តគម្រោង SEIP និងគម្រោង GEIP។ ពង្រីកការអនុវត្តឧត្តមានុវត្តដែលមានស្រាប់នៅគ្រប់កម្រិតសិក្សាដើម្បីប្រែក្លាយសាលាគ្រប់កម្រិតទៅជាសាលាដែលសម្រេចបានស្តង់ដាសាលាគំរូ។

## តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

- មធ្យោបាយសម្រាប់សម្រេចបានគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីព៖
  - ថវិកាគម្រោង GEIP HEIP និងថវិកា PIP (ប្រើប្រាស់ថវិការដ្ឋដើម្បីបង្កើនចំនួនអ្នកសិក្សាកម្មវិធី TUP/LUP)
  - ផ្សារភ្ជាប់នឹងកំណែទម្រង់រដ្ឋបាលដើម្បីជំរុញ និងផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលប្រឹងប្រែងការងារ


ប្រព័ន្ធផ្សារភ្ជាប់គ្នា
កម្មវិធីកំណែទម្រង់សាលារៀន
កម្មវិធីបណ្តុះបណ្តាលគ្រូ
គោលនយោបាយ
សហគមន៍
សាលារៀនទាំង ៣ អនុវិស័យ
គុណផលសិក្សាសិស្សគ្រប់កម្រិត
ក្រសួង
មន្ត្រី
សិស្ស/និស្សិតទទួលបានជំនាញសតវត្សទី ២១


ធ្វើឱ្យជឿជាក់លើយន្តការគ្រប់គ្រង
ក្រសួង មន្ទីរ និង
ការិយាល័យអប់រំស្រុក
ពង្រីកការអនុវត្តស្តង់ដា
សាលាគំរូទៅគ្រប់សាលា
រៀនក្នុងគ្រប់ខេត្ត ក្រុង
ស្រុក ឃុំសង្កាត់
គ្រប់គ្រឹះស្ថានបណ្តុះបណ្តាល
គ្រូទាំងអស់គាំទ្រសាលា
សម្រេចបានស្តង់ដាសាលាគំរូ
សាលារៀនជាប់ស្តង់ដាបង្ហាត់
បង្ហាញដល់សាលារៀនផ្សេង
ទៀតដើម្បីសម្រេចស្តង់ដា
សាលារៀនគំរូ

## ប្រព័ន្ធផ្សារភ្ជាប់គ្នា

- ការសម្រេចចិត្ត៖ អញ្ជើញក្រុមគ្រួសារសិស្សចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្ត និងការកំណត់គោលដៅរបស់សាលារៀនតាមរយៈកិច្ចសហប្រតិបត្តិការរួមជាមួយនឹងគ្រូបង្រៀន
- កិច្ចទំនាក់ទំនង៖ ប្រើប្រាស់យុទ្ធសាស្ត្រដែលលើកទឹកចិត្តឱ្យមានកិច្ចទំនាក់ទំនងទ្វេទិសរវាងមាតាបិតាសិស្ស និងគ្រូបង្រៀនឱ្យទាន់ពេលវេលានិងជាប្រចាំ
- ការអនុវត្តការបង្រៀន៖ ធ្វើការងារដោយជិតស្និតជាមួយគ្រួសារសិស្សដោយបង្ហាញពីគោលដៅ គោលបំណងដើម្បីយល់ដឹងច្បាស់ពីជីវភាពរស់នៅរបស់សិស្ស គ្រួសារសិស្ស និងសហគមន៍ ដើម្បីបញ្ចូលចំណេះដឹងមាតាបិតាសិស្សទៅក្នុងកម្មវិធីសិក្សា និងការអនុវត្តការបង្រៀន

## ប្រព័ន្ធផ្សារភ្ជាប់គ្នា

- ការសិក្សានៅគេហដ្ឋាន៖ ផ្តល់របៀបអនុវត្តដើម្បីគាំទ្រដល់ការខិតខំប្រឹងប្រែងរបស់មាតាបិតាក្នុងការពង្រឹងការសិក្សារៀនសូត្ររបស់កូននៅគេហដ្ឋាន និងក្នុងសហគមន៍សិក្សារៀនសូត្រនៅក្រៅសាលារៀន។
- ការរៀបចំការងារ/ការអភិវឌ្ឍគម្រោងការនានា៖ អញ្ជើញក្រុមគ្រួសារសិស្សដើម្បីចូលរួមដោយសកម្មក្នុងការសម្រេចចិត្តលើការចូលរួមកម្មវិធីផ្សេងៗរបស់សាលារៀនដើម្បីជំរុញការសិក្សារៀនសូត្ររបស់កូន
- ការផ្លាស់ប្តូរប្រព័ន្ធ៖ ស្ថាប័ននីយកម្មក្នុងការចូលរួមអនុវត្តកិច្ចការចាំបាច់ និងគោលនយោបាយនានាដើម្បីគ្រូបង្រៀនជួយគាំទ្រពេញទំហឹងក្នុងការសិក្សារៀនសូត្ររបស់សិស្សឆ្លើយតបនឹងការចូលរួមរបស់មាតាបិតា។


ប្រព័ន្ធផ្សារភ្ជាប់គ្នា
សាលាគោលដៅអនុវត្តគោលការណ៍ឋាមពលរបស់ក្រុមគ្រួសារសិស្ស (ខុសពីគោលគំនិតដែលថាគ្រួសារសិស្សក្រីក្រ/ខ្វះខាត) ជំនួសឱ្យការមិនទទួលបានអ្វីដែលគ្រួសារសិស្សគ្មាន សាលារៀនត្រូវគិតពីអ្វីដែលក្រុមគ្រួសារសិស្សអាចចូលរួមបានដើម្បីពង្រឹងភាពជាដៃគូ ឧទាហរណ៍បទពិសោធន៍របស់ក្រុមគ្រួសារសិស្សក្នុងសហគមន៍ ឬក្នុងការអប់រំកូនចៅរបស់ពួកគាត់
ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនគឺជាដំណើរការសម្រាប់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្ស៖ ក្រុមគ្រួសារ និងសាលារៀនធ្វើការងារជាមួយគ្នាដើម្បីទទួលបាននូវការយល់គ្នាទៅវិញទៅមកលើទស្សនវិស័យ និងកំណត់គុណតម្លៃចែករំលែក ព្រមទាំងគោលដៅអប់រំសម្រាប់សិស្ស/កូនចៅ
ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនត្រូវចាត់ជាសមាសធាតុស្នូលនៃសមធម៌ និងការអប់រំប្រកបដោយប្រសិទ្ធភាព៖ ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនគឺចាំបាច់សម្រាប់ភាពជោគជ័យរបស់សិស្ស ក្នុងន័យនេះ សមាសភាពនេះត្រូវបានចាត់ទុកថាជាសមាសធាតុគន្លឹះជោគជ័យនៃវិស័យអប់រំ។

# គោលការនៃការប្រតបត្ត ការអភវឌ្ឍវជ្ជាជីវៈជា ប្រចាំ និងគន្លងអាជីព

## តើអ្វីទៅជាការវិភាគបែប SWOT

- ការវិភាគបែប គឺជាមធ្យោបាយតែមួយគត់សម្រាប់កំណត់ភាពខ្លាំង ភាពខ្សោយ កាទ្បានុវត្តភាព និងបញ្ហាប្រឈម សម្រាប់ការងារគ្រប់គ្រងគ្រឹះស្ថានសិក្សាសម្រេចបានស្តង់ដាសាលារៀនគំរូ។
- តារាងវិភាគ SWOT ជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជួយស្វែងរកកាទ្បានុវត្តភាពក្នុងការកែលម្អគ្រឹះស្ថានសិក្សា ជាពិសេសការបង្កើនចំណេះដឹង និងចំណេះធ្វើរបស់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យអប់រំ។


តើ SWOT មានន័យដូចម្ដេច?
Strengths៖ ភាពខ្លាំងអាចសំដៅទៅលើលក្ខណៈវិជ្ជមាន ជំនាញ និងគុណលក្ខណៈជាច្រើនដែលបុគ្គលមាន។
S
W
weaknesses៖ ចំណុចខ្សោយសំដៅដល់ចំណុចអវិជ្ជមានដែលធ្វើឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍ ការរីកចម្រើន ការលូតលាស់។ ការកំណត់ចំណុចខ្សោយអាចសំខាន់ដូចជាការទទួលស្គាល់ចំណុចខ្លាំងដែរ។ នេះគឺជាឧទាហរណ៍ទូទៅមួយចំនួននៃភាពទន់ខ្សោយ៖
Opportunities៖ ឱកាសអាចមានច្រើនទម្រង់ ហើយការទទួលស្គាល់វាជាគន្លឹះនៃការរីកចម្រើនផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។
O
T
Threats៖ ការគម្រាមកំហែង គឺជាការបង្ហាញអំពីចេតនាបង្កគ្រោះថ្នាក់ ឬការខូចខាត ឬការបង្ហាញអំពីអ្វីមួយដែលជិតមកដល់ ដែលអាចបង្កគ្រោះថ្នាក់


ភាពខ្លាំង
ខាងក្រោមនេះជាឧទាហរណ៍មួយចំនួនពាក់ព័ន្ធនឹងភាពខ្លាំង៖
ភាពខ្លាំងបុគ្គល៖
ជំនាញ និងទេពកោសល្យ៖ ជំនាញក្នុងផ្នែកជាក់លាក់ ដូចជាទំនាក់ទំនង ភាពជាអ្នកដឹកនាំ ឬជំនាញបច្ចេកទេស។
•លក្ខណៈវិជ្ជមាន៖ គុណលក្ខណៈដូចជា ភាពធន់ ភាពច្នៃប្រឌិត និងភាពប្រែប្រួល។
•សុខភាព និងសុខុមាលភាព៖ សុខភាពផ្លូវកាយ និងផ្លូវចិត្តល្អ។
ភាពខ្លាំងនៃអង្គភាព៖
ភាពជាអ្នកដឹកនាំខ្លាំង៖ ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងមានចក្ខុវិស័យ។
•វប្បធម៌ច្នៃប្រឌិត៖ ការលើកទឹកចិត្តដល់ការច្នៃប្រឌិត និងការច្នៃប្រឌិត។
•ស្ថិរភាពហិរញ្ញវត្ថុ៖ សុខភាពហិរញ្ញវត្ថុរឹងមាំ និងធនធាន។
ភាពខ្លាំងជាប្រព័ន្ធ៖
សុវត្ថិភាពរឹងមាំ៖ វិធានការសន្តិសុខតាមអ៊ីនធឺណិតរឹងមាំ និងសុវត្ថិភាពរាងកាយ។
•ហេដ្ឋារចនាសម្ព័ន្ធទំនើប៖ ហេដ្ឋារចនាសម្ព័ន្ធទំនើប និងមានប្រសិទ្ធភាព។
•ការអនុលោមតាមបទប្បញ្ញត្តិ៖ ការប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិនិងស្តង់ដារ។


ចំណុចខ្សោយ
ចំណុចខ្សោយផ្ទាល់ខ្លួន៖
1.គម្លាតជំនាញ៖ ខ្វះជំនាញ ឬចំណេះដឹងជាក់លាក់។
• បញ្ហាសុខភាព៖ បញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្ត។
• ចរិតលក្ខណៈ៖ លក្ខណៈដូចជាការពន្យារពេល ឬការគ្រប់គ្រងពេលវេលាមិនល្អ។
ភាពទន់ខ្សោយរបស់អង្គភាព៖
1.ដែនកំណត់ធនធាន៖ ធនធានហិរញ្ញវត្ថុ មនុស្ស ឬធនធានបច្ចេកវិទ្យាមិនគ្រប់គ្រាន់។
• ដំណើរការងារការគ្មានប្រសិទ្ធភាព៖ ដំណើរការ និងប្រព័ន្ធមិនមានប្រសិទ្ធភាព ឬហួសសម័យ។
• ទីតាំងទីផ្សារ៖ វត្តមានម៉ាកយីហោខ្សោយ ឬចំណែកទីផ្សារ។
ភាពទន់ខ្សោយជាប្រព័ន្ធ៖
1.ភាពងាយរងគ្រោះផ្នែកសុវត្ថិភាព៖ ភាពទន់ខ្សោយនៃសន្តិសុខតាមអ៊ីនធឺណិត ឬសុវត្ថិភាពរាងកាយ។
• បញ្ហាហេដ្ឋារចនាសម្ព័ន្ធ៖ ភាពចាស់ជរា ឬហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់។
• ការអនុលោមតាមបទប្បញ្ញត្តិ៖ ការលំបាកក្នុងការបំពេញតម្រូវការបទប្បញ្ញត្តិ។


ឱកាស
ឱកាសផ្ទាល់ខ្លួន៖
1.វឌ្ឍនភាពអាជីព៖ ការផ្សព្វផ្សាយ ការផ្តល់ជូនការងារថ្មី ឬការអភិវឌ្ឍវិជ្ជាជីវៈ។
2.ការអប់រំ៖ អាហារូបករណ៍ វគ្គបណ្តុះបណ្តាល ឬកម្មវិធីបណ្តុះបណ្តាល។
3.បណ្តាញ៖ ការកសាងទំនាក់ទំនងជាមួយមនុស្សមានឥទ្ធិពលនៅក្នុងវិស័យរបស់អ្នក។
ឱកាសក្នុងអាជីព៖
1. ការពង្រីកទីផ្សារ៖ ចូលទីផ្សារថ្មី ឬបើកដំណើរការផលិតផលថ្មី។
2.ភាពជាដៃគូ៖ សហការជាមួយអាជីវកម្ម ឬអង្គការផ្សេងៗ។
3.នវានុវត្តន៍៖ អភិវឌ្ឍបច្ចេកវិទ្យាថ្មី ឬកែលម្អដំណើរការដែលមានស្រាប់។
ឱកាសសហគមន៍៖
1. ការងារស្ម័គ្រចិត្ត៖ ចូលរួមក្នុងសេវាកម្មសហគមន៍ ឬបុព្វហេតុសង្គម។
2.គំនិតផ្តួចផ្តើមក្នុងស្រុក៖ ចូលរួមក្នុងគម្រោង ឬព្រឹត្តិការណ៍ក្នុងស្រុក។
3.ជំនួយ និងថវិកា៖ ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោងសហគមន៍។

# ការប្រឈម/គំរាមកំហែង

- ការគំរាមកំហែងសង្គម៖ ហានិភ័យដល់ស្ថិរភាពសង្គម ដូចជាចលាចលនយោបាយ ឬជម្លោះសង្គម។
- ការគំរាមកំហែងផ្នែកសេដ្ឋកិច្ច៖ ហានិភ័យហិរញ្ញវត្ថុដែលអាចប៉ះពាល់ដល់សេដ្ឋកិច្ច ឬអាជីវកម្ម។
- ការគំរាមកំហែងផ្នែកបរិស្ថាន៖ គ្រោះមហន្តរាយធម្មជាតិ ឬការផ្លាស់ប្តូរបរិស្ថានដែលបង្កហានិភ័យដល់អាយុជីវិត និងទ្រព្យសម្បត្តិ។
- ការគំរាមកំហែងតាមអ៊ីនធឺណិត៖ ហានិភ័យទាក់ទងនឹងសុវត្ថិភាពឌីជីថល ដូចជាការលួចចូល ឬការរំលោភបំពានទិន្នន័យជាដើម។
- ការគំរាមកំហែងខាងរាងកាយ៖ ការបង្ហាញពីការបង្កគ្រោះថ្នាក់ដល់រាងកាយ ឬអំពើហឹង្សាដែលអាចកើតមាន។

# តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

a. **គោលដៅ និងជម្រើសគោលនយោបាយរបស់ជាតិជាគោលសម្រាប់រៀបចំផ្លូវ និងជម្រើសសកម្មភាពរបស់គ្រឹះស្ថានសិក្សា**

- ចក្ខុវិស័យរបស់ជាតិ «២០៣០ ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់» និងជម្រើសរបស់ជាតិ «កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព» ត្រូវបានប្រើប្រាស់ និងចាំបាច់ត្រូវអនុវត្តតាមដើម្បីចំណេញពេលវេលាក្នុងការសម្រេចបានចក្ខុវិស័យនេះក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំ។

b. **ពន្លឿនកំណែទម្រង់ក្នុងអភិបាលកិច្ចគ្រឹះស្ថានសិក្សាដើម្បីកែលម្អប្រសិទ្ធភាពការងារ និងគុណផល**

- ដើម្បីពន្លឿនកំណែទម្រង់គ្រឹះស្ថានសិក្សា ការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រសាលារៀនគំរូ ដែលផ្តោតលើភាពជាអ្នកដឹកនាំបែបចែករំលែក ការកសាងសមត្ថភាពមនុស្ស ការកែលម្អភាពស្អាតស្អំ និងតម្លាភាព ការគ្រប់គ្រងគុណផល និងការផ្តល់រង្វាន់លើកទឹកចិត្ត កិច្ចសន្យាសាធារណៈលើលទ្ធផលដើម្បីកសាងគណនេយ្យភាព និងជំរុញភាពជាម្ចាស់។

## តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

c. **កសាងមូលធនមនុស្សផ្អែកលើសមត្ថភាពបុគ្គល ផ្លាស់ប្តូរផ្នត់គំនិត កំណែទម្រង់ប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលបន្ត**

- បទពិសោធន៍គម្រោង SEIP គឺបានធ្វើឱ្យការអភិវឌ្ឍសមត្ថភាពមនុស្សមានដំណើរការដោយប្រើប្រាស់ និងយកគំរូពីបទពិសោធន៍សកលលោក ឧ. សកលភាវូនីយកម្មកម្មវិធីបណ្តុះបណ្តាលបន្ត។ កម្មវិធី និងប្រព័ន្ធបណ្តុះបណ្តាលបន្តបានធ្វើឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនទទួលបានការយល់ដឹងថ្មី ផ្លាស់ប្តូរទម្លាប់ ទទួលយកអាកប្បកិរិយាថ្មី និងទទួលបានចំណេះដឹងថ្មីៗដើម្បីធ្វើឱ្យប្រព័ន្ធសាលារៀនមានភាពប្រទាក់ក្រឡាគ្នា និងមានដំណើរការដោយរលូន។

## តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

- **លើសពីនោះទៅទៀត ផែនការសកម្មភាពរយៈពេលមធ្យមនេះគឺជាឧបករណ៍គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈ២០២៤ ដល់ ២០២៨ របស់រាជរដ្ឋាភិបាល។ ក្រុមការងារគម្រោងសម្របសម្រួលក្នុងការអនុវត្តផែនការសកម្មភាពរយៈពេលមធ្យមដើម្បីឱ្យសាលារៀនក្នុងគម្រោងនៅក្នុងទាំង ៣ អនុវិស័យសម្រេចបានស្តង់ដាសាលារៀនគំរូ**
- សៀវភៅណែនាំប្រតិបត្តិស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពសម្រាប់មន្ត្រីអប់រំត្រូវបានរៀបចំដោយផ្អែកលើឧត្តមានុវត្ត និងភាពជោគជ័យនៃការអនុវត្តគម្រោង SEIP និងគម្រោង GEIP។ ពង្រីកការអនុវត្តឧត្តមានុវត្តដែលមានស្រាប់នៅគ្រប់កម្រិតសិក្សាដើម្បីប្រែក្លាយសាលាគ្រប់កម្រិតទៅជាសាលាដែលសម្រេចបានស្តង់ដាសាលាគំរូ។

## តើត្រូវបន្តកិច្ចការអ្វីជាបន្តទៀត?

- មធ្យោបាយសម្រាប់សម្រេចបានគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីព៖
  - ថវិកាគម្រោង GEIP HEIP និងថវិកា PIP (ប្រើប្រាស់ថវិការដ្ឋដើម្បីបង្កើនចំនួនអ្នកសិក្សាកម្មវិធី TUP/LUP)
  - ផ្សារភ្ជាប់នឹងកំណែទម្រង់រដ្ឋបាលដើម្បីជំរុញ និងផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលប្រឹងប្រែងការងារ

## ប្រព័ន្ធផ្សារភ្ជាប់គ្នា




ធ្វើឱ្យជឿជាក់លើយន្តការគ្រប់គ្រង
ក្រសួង មន្ទីរ និង ការិយាល័យអប់រំស្រុក ពង្រីកការអនុវត្តស្តង់ដាសាលាគំរូទៅគ្រប់សាលារៀនក្នុងគ្រប់ខេត្ត ក្រុង ស្រុក ឃុំសង្កាត់
គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូទាំងអស់គាំទ្រសាលាសម្រេចបានស្តង់ដាសាលាគំរូ
សាលារៀនជាប់ស្តង់ដាបង្ហាត់បង្ហាញដល់សាលារៀនផ្សេងទៀតដើម្បីសម្រេចស្តង់ដាសាលារៀនគំរូ


ប្រព័ន្ធផ្សារភ្ជាប់គ្នា
ការសម្រេចចិត្ត
អញ្ជើញក្រុមគ្រួសារសិស្សចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្ត និងការកំណត់គោលដៅរបស់សាលារៀនតាមរយៈកិច្ចសហប្រតិបត្តិការរួមជាមួយនឹងគ្រូបង្រៀន
កិច្ចទំនាក់ទំនង
ប្រើប្រាស់យុទ្ធសាស្ត្រដែលលើកទឹកចិត្តឱ្យមានកិច្ចទំនាក់ទំនងទ្វេទិសរវាងមាតាបិតាសិស្ស និងគ្រូបង្រៀនឱ្យទាន់ពេលវេលានិងជាប្រចាំ
ការអនុវត្តការបង្រៀន
ធ្វើការងារដោយជិតស្និតជាមួយគ្រួសារសិស្សដោយបង្ហាញពីគោលដៅគោលបំណងដើម្បីយល់ដឹងច្បាស់ពីជីវភាពរស់នៅរបស់សិស្ស គ្រួសារសិស្ស និងសហគមន៍ ដើម្បីបញ្ចូលចំណេះដឹងមាតាបិតាសិស្សទៅក្នុងកម្មវិធីសិក្សា និងការអនុវត្តការបង្រៀន

## ប្រព័ន្ធផ្សារភ្ជាប់គ្នា

ការសិក្សានៅគេហដ្ឋាន

ការរៀបចំការងារ/ការអភិវឌ្ឍគម្រោងការនានា

**ការផ្លាស់ប្តូរប្រព័ន្ធ**

- ផ្តល់របៀបអនុវត្តដើម្បីគាំទ្រដល់ការខិតខំប្រឹងប្រែងរបស់មាតាបិតាក្នុងការពង្រឹងការសិក្សារៀនសូត្ររបស់កូននៅគេហដ្ឋាន និងក្នុងសហគមន៍សិក្សារៀនសូត្រនៅក្រៅសាលារៀន។
- អញ្ជើញក្រុមគ្រួសារសិស្សដើម្បីចូលរួមដោយសកម្មក្នុងការសម្រេចចិត្តលើការចូលរួមកម្មវិធីផ្សេងៗរបស់សាលារៀនដើម្បីជំរុញការសិក្សារៀនសូត្ររបស់កូន
- ស្ថាប័ននីយកម្មក្នុងការចូលរួមអនុវត្តកិច្ចការចាំបាច់ និងគោលនយោបាយនានាដើម្បីគ្រូបង្រៀនជួយគាំទ្រពេញទំហឹងក្នុងការសិក្សារៀនសូត្ររបស់សិស្សឆ្លើយតបនឹងការចូលរួមរបស់មាតាបិតា។

## ប្រព័ន្ធផ្សារភ្ជាប់គ្នា

- សាលាគោលដៅអនុវត្តគោលការណ៍ឋាមពលរបស់ក្រុមគ្រួសារសិស្ស (ខុសពីគោលគំនិតដែលថាគ្រួសារសិស្សក្រីក្រ/ខ្វះខាត) ជំនួសឱ្យការមិនទទួលបានអ្វីដែលគ្រួសារសិស្សគ្មាន សាលារៀនត្រូវគិតពីអ្វីដែលក្រុមគ្រួសារសិស្សអាចចូលរួមបានដើម្បីពង្រឹងភាពជាដៃគូ ឧទាហរណ៍បទពិសោធន៍របស់ក្រុមគ្រួសារសិស្សក្នុងសហគមន៍ ឬក្នុងការអប់រំកូនចៅរបស់ពួកគាត់
- ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនគឺជាដំណើរការសម្រាប់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្ស៖ ក្រុមគ្រួសារ និងសាលារៀនធ្វើការងារជាមួយគ្នាដើម្បីទទួលបាននូវការយល់គ្នាទៅវិញទៅមកលើទស្សនវិស័យ និងកំណត់គុណតម្លៃចែករំលែក ព្រមទាំងគោលដៅអប់រំសម្រាប់សិស្ស/កូនចៅ
- ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនត្រូវចាត់ជាសមាសធាតុស្នូលនៃសមធម៌ និងការអប់រំប្រកបដោយប្រសិទ្ធភាព ៖ ការចូលរួមរបស់ក្រុមគ្រួសារ-សាលារៀនគឺចាំបាច់សម្រាប់ភាពជោគជ័យរបស់សិស្ស ក្នុងន័យនេះ សមាសភាពនេះត្រូវបានចាត់ទុកថាជាសមាសធាតុគន្លឹះជោគជ័យនៃវិស័យអប់រំ។

# ទំនួលខុសត្រូវ និងភាតព្វកិច្ចរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន

គោលបំណងនៃមេរៀន៖ ដឹង និងទទួលយកការទទួលខុសត្រូវ និងកាតព្វកិច្ច ដើម្បីចូលរួមចំណែកសម្រេចបានចក្ខុវិស័យ ២០៣០ និង២០៥០ របស់រាជរដ្ឋាភិបាល

តើជីវិតបែបណាដែលអ្នកចង់បាន ?

តើជីវិតបែបណាដែលអ្នកចង់បាន ?
ជីវិតប្រកបដោយមោទនភាព ប្រកបដោយភាពស៊ីវិល័យ និងសមត្ថភាពវិជ្ជាជីវៈ (ចំណេះដឹង ចំណេះធ្វើ ការសិក្សារៀនសូត្រ សីលធម៌ និងគុណធម៌)

ប្រសិនបើអ្នកមិនអាចរស់នៅក្នុងជីវិតមួយដែលអ្នកចង់បាន សួរថាហេតុអ្វី ?
តើវាលំបាកមហាសែនលំបាកទៅឬក្នុងការផ្លាស់ប្តូរជីវិតបែបនោះ ?
ផ្លាស់ប្តូរជីវិតរបស់អ្នកគឺចាប់ផ្តើមដំបូងពីការផ្លាស់ប្តូរផ្នត់គំនិត ឬផ្លាស់ប្តូររបៀបក្នុងការគិត។
តើហេតុអ្វីបានជាលំបាកម្ល៉េះបើគ្រាន់តែផ្លាស់ប្តូរផ្នត់គំនិត ឬផ្លាស់ប្តូររបៀបគិតរបស់អ្នក ?

តើអ្នកដឹងពីទំនោរឆ្ពោះទៅមុខនៃប្រព័ន្ធអេកូអប់រំដែរឬទេ ?

*i. បង្កើនភាពជោគជ័យ និងការចូលរៀននៅកម្រិតអប់រំចំណេះទូទៅ*
*ii. យុវជនក្រៅសាលាមានឱកាសក្នុងការទទួលបានផលពីប្រព័ន្ធអប់រំ*
*iii. យុវជនត្រូវទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់នៅគ្រប់កម្រិត*
*iv. យុវជនត្រូវបំពាក់ជំនាញចិត្តសង្គមច្បាស់លាស់*

*តើទាំងនេះមានន័យយ៉ាងណាដែរចំពោះអ្នក ?*

តើអ្នកមានដឹងពីចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ដែលត្រូវបានអនុម័តនៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០២២ ដែរឬទេ ?


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ចក្ខុវិស័យនិងយុទ្ធសាស្ត្រ
ស្តីពី
សុខដុមនីយកម្មការកែទម្រង់ ៣ ជុំ ១

២០២២

## បុព្វកថា

“**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**” ត្រូវបានកំណត់យកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលប្រការនេះជាសក្ខីកម្មអំពីរបៀបវារៈគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមិនត្រឹមតែបន្តយកចិត្តទុកដាក់លើការងារកែទម្រង់ តែលើសពីនេះ គឺការបង្កើនអាទិភាពលើការងារកែទម្រង់ ជាងពេលណាៗទាំងអស់។

ទន្ទឹមនេះ អភិក្រម ៥ ប្រការ គឺ “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**” ដែលខ្ញុំបានដាក់ចេញកាលពីដើមអាណត្តិទី៥នៃរាជរដ្ឋាភិបាល នៅតែជាអភិក្រមកែទម្រង់ដ៏មុតស្រួចនិងត្រូវបន្តប្រកាន់យកសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ដើម្បីចូលរួមចំណែកដល់ការសម្រេចបាននូវគោលដៅនៃការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចនេះ។

ការកែទម្រង់បានក្លាយទៅជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក៏ប៉ុន្តែការកែទម្រង់មិនមែនទើបតែត្រូវបានចាប់ផ្តើមនោះឡើយ ផ្ទុយទៅវិញ យើងបានធ្វើការងារនេះអស់រយៈពេល ៤ ទសវត្សមកហើយ។ ហេតុនេះ ក្នុងនាមជាប្រមុខដឹកនាំរាជរដ្ឋាភិបាល ខ្ញុំតែងមានទស្សនៈមួយថា “**រដ្ឋាភិបាលរបស់ប្រជាជន ដោយសារប្រជាជន និងដើម្បីប្រជាជន**” ដ៏ពិតប្រាកដគឺជារដ្ឋាភិបាលដែលយល់ច្បាស់អំពីគុណតម្លៃនៃការកែទម្រង់និងមោះមុតក្នុងការងារនេះជាប់ជាប្រចាំទៅតាមតម្រូវការនៃគ្រប់កាលៈទេសៈ ដើម្បីធានាចីរភាពនៃរដ្ឋបាលសាធារណៈ ប្រសិទ្ធភាពនៃសេវាសាធារណៈ និងសុខុមាលភាពនិងជីវភាពកាន់តែប្រសើររបស់ប្រជាពលរដ្ឋ។

យើងបានចាប់ផ្តើមការងារកែទម្រង់តាំងពីក្នុងគ្រាដែលកម្ពុជាទើបរួចចាកផុតពីរបបប្រល័យពូជសាសន៍មកម៉្លេះ ដែលពេលនោះអាទិភាពចាំបាច់ទីមួយរបស់យើងមិនមែនការអភិវឌ្ឍធនធានមនុស្ស ផ្លូវ ទឹក និងភ្លើងដូចសព្វថ្ងៃនេះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ អាទិភាពដែលយើងត្រូវដោះស្រាយជាចាំបាច់ គឺបញ្ចប់ការអត់ឃ្លាន ហើយគោលដៅសំខាន់បំផុតនៃការកែទម្រង់របស់យើងនាពេលនោះ គឺ ***ការរកដំណោះស្រាយបញ្ចប់ភាពក្រីក្ររបស់ប្រជាជនយើង***។ ចំណុចនេះជាការបកស្រាយមួយទៅលើប្រវត្តិនៃទិសស្លោកគន្លឹះដែលខ្ញុំតែងតែលើកឡើងនិងរំលឹកជាប់ជាប្រចាំថា “**កែទម្រង់ រស់, មិនកែទម្រង់ ស្លាប់**”។ ក្នុងសម័យសន្តិភាព ថ្វីត្បិតអាទិភាពនៃការកែទម្រង់របស់យើងមានការផ្លាស់ប្តូរទៅតាមតម្រូវការសង្គមកំពុងអភិវឌ្ឍល្ងូតលាស់ ទិសស្លោកមួយនេះនៅតែជាគំនិតដឹកនាំដ៏ត្រឹមត្រូវនិងប្រកបដោយសច្ចធម៌ ដែលថ្នាក់ដឹកនាំនិងមន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ត្រូវឈ្វេងយល់និងប្រកាន់ខ្ជាប់ ជាពិសេស ត្រូវចៀសវាងសេចក្តីយល់ខុសថាការងារកែទម្រង់គឺជាបន្ទុកបន្ថែមលើការបំពេញមុខងារនិងភារកិច្ចប្រចាំថ្ងៃ។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** ត្រូវបានរៀបចំឡើងដោយអនុលោមតាមអភិក្រមចំនួន ៤ គឺ ÷ **ទី១) អភិក្រមរក្សាតំហើញទាំងមូល** ដែលសំដៅប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន, **ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី** សំដៅដល់កម្មវិធីកែទម្រង់នីមួយៗបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន, **ទី៣) អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ** គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផងនិងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតផង និង **ទី៤) អភិក្រមបុរេសកម្ម** គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នាតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

ខ្ញុំរំពឹងថាឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** នេះ ជាមគ្គុទេសក៍បង្ហាញផ្លូវដ៏ល្អសម្រាប់ការអនុវត្តយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក១ សំដៅសម្រេចបាននូវចក្ខុវិស័យ សុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១ ដូចដែលបានកំណត់រួមគ្នា។ ជាមួយគ្នានេះ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ថាប័ននិងអង្គភាពដែលជាតួអង្គពាក់ព័ន្ធទាំងអស់ដកស្រង់បទពិសោធន៍និងមេរៀនល្អៗ ដែលកើតចេញពីកិច្ចដំណើរការនិងការអនុវត្តនៃឯកសារនេះ ធ្វើជាមូលដ្ឋានក្នុងការកែទម្រង់សម្រាប់ការបោះជំហានបន្ទាប់ ជាបន្តទៀត សំដៅពង្រឹងគុណភាពអភិបាលកិច្ច ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា ឱ្យបានកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ២កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ជំពូកទី២. ចក្ខុវិស័យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១

## ១.១. ចក្ខុវិស័យនិងបេសកកម្មសម្រាប់កម្មវិធីកែទម្រង់ ៣ បូក ១

### ១.១.១. ចក្ខុវិស័យ

កម្មវិធីកែទម្រង់ ៣ បូក ១ មានចក្ខុវិស័យដោយឡែកពីគ្នាទៅតាមវិសេសភាពនិងវិស័យរៀងៗខ្លួន ដែលមានដូចតទៅ÷

### ១.៣.២.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺ “***ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ននិងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ធំទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០***”។

### ១.៣.២.២. គោលបំណង

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានគោលបំណង ***"លើកកម្ពស់ការផ្តល់សេវានិងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង"***។

## ១.៣. ស្ថានភាពបច្ចុប្បន្ន

### ១.៣.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចក្ខុវិស័យច្បាស់លាស់គឺប្រែក្លាយ "***ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការស្របតាមស្តង់ដារនិងខ្នាតគំរូមានវត្តន៍អន្តរជាតិ***"។

### ១.២.១.៣. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ

ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបន្តកិច្ចប្រឹងប្រែងក្នុងការកសាងរដ្ឋបាលសាធារណៈ ដែលមានលក្ខណៈ ខ្លាំង ស្អាតស្អំ ឆ្លាត និងផ្តោតលើប្រជាជន ជាស្នូល។ ក្នុងន័យនេះ ការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចគឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវអនុវត្តតាមរយៈការដ្ឋានកែទម្រង់និងកម្មវិធីទាំងឡាយរបស់រាជរដ្ឋាភិបាល ពិសេសការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ជាដើម។ នៅក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥ ត្រូវបានរៀបចំឡើងជាដំណាក់កាលៗ ដែលផ្តោតជាអាទិភាពលើការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ ដែលសកម្មភាពកែទម្រង់ទាំងអស់នេះមានសង្គតិភាព ភាពប្រទាក់ក្រឡា និងការគាំទ្រគ្នាទៅវិញទៅមកជាមួយនឹងការដ្ឋានកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល។

## យុទ្ធសាស្ត្របញ្ចកោណ

### ដំណាក់កាលទី ១

### ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព

### កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច

### ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

| រចនាសម្ព័ន្ធយុទ្ធសាស្ត្របញ្ចកោណ | រចនាសម្ព័ន្ធយុទ្ធសាស្ត្រសហគមន៍សាលារៀន |
|---|---|
| *ចក្ខុវិស័យ* | *ចក្ខុវិស័យ* |
| • *បេសកកម្មៈ ចក្ខុវិស័យ២០៣០ និង ចក្ខុវិស័យ២០៥០* | • *បេសកកម្មៈ សមត្ថភាពសិស្សសម្រាប់ជីវិតនិងការងារ និងសមត្ថភាពដឹកនាំរបស់សាលារៀនបំពេញស្តង់ដា* |
| • *គោលដៅៈ កំណើន ការងារ សមធម៌ ប្រសិទ្ធិភាព និង ចីរភាព* | • *គោលដៅៈ សិស្សមានសមត្ថភាព៨០ទៅ៨៥% និង សហគមន៍សាលារៀនបំពេញស្តង់ដា ដោយពុំទុកចោលអ្នកម្នាក់ នៅឆ្នាំ២០២៨* |
| • *យុទ្ធសាស្ត្រៈ ចំនួន៥ បញ្ចកោណទី១ មូលធនមនុស្ស* | • *យុទ្ធសាស្ត្រៈ ចំនួន៦ បូកជាមួយវប្បធម៌និងគុណតម្លៃ* |
| *រចនាសម្ព័ន្ធអនុវត្តយុទ្ធសាស្ត្រៈ ចូលរួមដោយគ្រប់ភាគីពាក់ព័ន្ធ ១៦ស្ថាប័ណ*<br>• *យុទ្ធសាស្ត្រស្នូល អភិបាលកិច្ច* | *រចនាសម្ព័ន្ធអនុវត្តយុទ្ធសាស្ត្រៈ ចូលរួមដោយគ្រប់ភាគីពាក់ព័ន្ធកម្រិតក្រុងស្រុកខ័ណ្ឌ*<br>• *អភិបាលកិច្ចស្ថាប័ន និង អភិបាលកិច្ចសហគមន៍សាលារៀន បំពេញស្តង់ដាសាលារៀនគំរូ* |
| *រចនាសម្ព័ន្ធពិនិត្យតាមដាន និងវាយតម្លៃៈ កសុតាងនៃការប្តេជ្ញាចិត្ត*<br>• *រាល់ខែ រាល់៣ខែ និងចុងឆ្នាំ កម្រិតថ្នាក់ជាតិ និងរដ្ឋបាលក្រុងស្រុកខ័ណ្ឌ* | *រចនាសម្ព័ន្ធពិនិត្យតាមដាន និងវាយតម្លៃៈ កសុតាងនៃការប្តេជ្ញាចិត្ត*<br>• *ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ វាស់ស្ទង់ការរីកចម្រើនស្តង់ដា ជាមួយផែនការសង់បន្ត កម្រិតជាតិ មន្ទីរអប់រំ ការិយាល័យអប់រំ សហគមន៍សាលារៀន* |
| *ការពិនិត្យឡើងវិញពាក់កណ្តាលយុទ្ធសាស្ត្រៈ កសុតាងនៃការលះបង់*<br>• *ពាក់កណ្តាលអណត្តិទី១ ឆ្នាំ២០២៤ ចុងអណត្តិឆ្នាំ២០២៨ និង ពាក់កណ្តាលយុទ្ធសាស្ត្រ  កម្រិតថ្នាក់ជាតិ និងរដ្ឋបាលក្រុងស្រុកខ័ណ្ឌ* | *ការពិនិត្យឡើងវិញពាក់កណ្តាលយុទ្ធសាស្ត្រៈ កសុតាងនៃការលះបង់*<br>• *ការពិនិត្យឡើងវិញនៅឆ្នាំ២០២៤ និងចុងឆ្នាំ២០២៨ ជាមួយការវិវត្តទៅរកស្រុកសាលារៀន កម្រិតជាតិ មន្ទីរអប់រំ ការិយាល័យអប់រំ សហគមន៍សាលារៀន* |

# កសាងសមត្ថភាពធានាសមធម៌សង្គម និងកំណើនសេដ្ឋកិច្ច (អនុក្រឹត្យ៤១)

- ១. ចក្ខុវិស័យ ២០៣០ និង២០៥០
- ២. ភាពក្រីក្ររៀនសូត្រ និងសមធម៌សង្គម(គុណភាពនិងបរិមាណ)
- ៣. អនុវត្តអនុក្រឹត្យ៤១ គ្រប់គ្រងវិនិយោគសាធារណៈ
- ៤. របាយការណ៍PISA-D និងSEA PLM ខ្សោយគំហើញ និងស្តាប់អាចជាមូលហេតុ




### មុំទី៥. ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌, សមធម៌ និង បរិយាបន្ន

គោលដៅជាយុទ្ធសាស្ត្រ គឺការធ្វើពលភាវូបនីយកម្មពលរដ្ឋ (People Revitalization) ឱ្យមាន សមត្ថភាព, ផលិតភាព, សីលធម៌, គុណធម៌ , ចរិយាធម៌, ភាពអំណត់, សុចរិតភាព, វិន័យ, និង ការទទួលខុសត្រូវខ្ពស់; និង ការលើក-កម្ពស់ ស្មារតី និង មនសិការស្នេហាជាតិ, ការពារជាតិ, ឯកភាពជាតិ, ការចេះយកអាសាគ្នា, ការចែករំលែក, ការចូលរួម, គុណតម្លៃសង្គម, និង ស្មារតី គោរពច្បាប់, ស្រឡាញ់សន្តិភាព, វប្បធម៌, ប្រពៃណីទំនៀមទម្លាប់, អំពើល្អ, និង យុត្តិធម៌, សំដៅធានាបាននូវសិនិទ្ធភាពសង្គម (Social Cohesion) និង សុខដុម-រមនាសង្គម ។

**តើអ្នកដឹងច្បាស់ពីតួនាទី និងភារកិច្ចរបស់អ្នកដែរឬទេ ?**

# ច្បាប់
# ស្តីពី
# ការអប់រំ

ជំពូកទី ៥
គុណភាព និងប្រសិទ្ធភាពអប់រំ

មាត្រា ២១.- គុណភាព និងប្រសិទ្ធភាពអប់រំ

រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្តីត្រូវការខាងការសិក្សាជាមូល-ដ្ឋាន និងសេចក្តីត្រូវការជំនាញ សម្រាប់ធ្វើឱ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព ។

ឆ្នាំ ទី ៧ លេខ ៩៣ សត្តាហ៍ទី ៣ ថ្ងៃ ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ៩៨១០

រដ្ឋត្រូវយកចិត្តទុកដាក់បំពាក់សម្ភារៈបច្ចេកទេសសមស្រប និងទំនើបក្នុងការរៀន និងបង្រៀន ដើម្បីធានាឱ្យបានគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ស្តង់ដារជាតិអប់រំ ស្តង់ដារជាតិបណ្តុះបណ្តាល និង/ឬ ស្តង់ដារជាតិសមត្ថភាព ត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

# ច្បាប់
## ស្តីពី
## សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
## នៃ
## ព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣៥.-

ត្រូវហាមឃាត់ជាដាច់ខាត ចំពោះអ្នករាជការនូវប្រការខាងក្រោម ៖

១- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផល ប្រយោជន៍អ្វីមួយឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ ។

៣- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ។

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬ ដោយប្រយោល ។

៥- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។



៦- ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែល លក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាននិងបទបញ្ញត្តិនៃមាត្រានេះអាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យ ណាមួយដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាច កើតមានឡើងទៀតផង ។

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១២៦. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

## រាជរដ្ឋាភិបាល

**មាត្រា៨.-**

គ្រូបង្រៀនប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ។

គ្រូបង្រៀនមានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំណត់ការពន្យល់សំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន។

**មាត្រា៩.-**

គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ។

៦

គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈបង្រៀន។

**មាត្រា១៣.-**

គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬ ប្រមូលប្រាក់ក្រៅផ្លូវការ ឬ ធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ។

គ្រូបង្រៀនត្រូវជៀសវាងការប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា។

**មាត្រា១៤.-**

គ្រូបង្រៀនត្រូវជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់កិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា១៥**.-

គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងការពន្យល់ ការបកស្រាយ និងសម្របសម្រួលដល់អ្នកសិក្សា នូវចំណេះដឹងនានា ស្របតាមមុខវិជ្ជា ឬ ឯកទេសរបស់ខ្លួន។

**មាត្រា១៦**.-

គ្រូបង្រៀនមានករណីយកិច្ចជួយអ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាលអ្នកសិក្សា ដោយមិនរើសអើង។



គ្រូបង្រៀនត្រូវជួយបង្រៀនបន្ថែមដល់អ្នកសិក្សារៀនយឺត។

**មាត្រា១៧**.-

គ្រូបង្រៀនត្រូវដឹកនាំសកម្មភាពសិក្សាក្នុងថ្នាក់ និងក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សាជាប់ជាប្រចាំ។

គ្រូបង្រៀនមានករណីយកិច្ចបង្រៀន ដោយមិនត្រូវដាក់សម្ពាធយកជាប្រយោជន៍លើអ្នកសិក្សាឡើយ។

**មាត្រា១៨**.-

គ្រូបង្រៀនត្រូវជួយសម្រួលដល់អ្នកសិក្សា ក្នុងការទទួលបាននូវផលប្រយោជន៍សង្គមដោយមិនលម្អៀង និងមានទំនាក់ទំនងជាមួយមាតាបិតា ឬ អ្នកអាណាព្យាបាលរបស់អ្នកសិក្សា ដើម្បីតាមដានលើរាល់សកម្មភាពសិក្សា។

តើនរណាជាអតិថិជនរបស់អ្នក?

- M

តើអតិថិជនរបស់អ្នកចង់បានអ្វីពីអ្នក?

- M

តើអ្នកដឹងថាត្រូវធ្វើបែបណាពីអ្វីដែលអតិថិជនរបស់អ្នកចង់បានដែរឬទេ?

- M

តើអ្នកបានធ្វើអ្វីខ្លះដើម្បីប្រទេសរបស់អ្នក?

- M

តើរាជរដ្ឋាភិបាលចង់បានអ្វីពីអ្នក?

- M

តើមាតាបិតាសិស្សចង់បានអ្វីពីអ្នក?

- M

តើអ្នកគិតថាអតិថិជនរបស់អ្នកចាប់អារម្មណ៍ពីអ្វីដែលបាន
បានធ្វើដែរឬទេ?

តើអ្នកគិតថាអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវា
ប្រកបដោយគុណភាពដែរឬទេ?

តើអ្នកគិតថាអង្គភាពរបស់អ្នកបានផ្តល់សេវាទាំងនោះដល់ប្រជាជនហើយឬនៅ?

***តើបើកសាលារៀនដើម្បីអ្វីទៅ?***

## ឧបករណ៍ តារាងសិស្សម្នាក់ចាកចេញផុតពីការអត់ឃ្លាន ភាពក្រីក្រ រស់មានជីវិតប្រសើរ និងមានសុខមាលភាព

| ថាមពលចំនួន១៖ ស្គាល់ខ្លួនឯង មានចំណេះដឹងពីកិច្ចការ និងសង្គមកំពុងរស់នៅជាមួយ | ថាមពលចរិយា៖ ផ្តោតលើចរិយាធ្វើការងារ និងចរិយាមានសីលធម៌ | ថាមពលពេលវេលា៖ ប្រើថាមពលពេលវេលាផ្តោតលើគោលបំណង និងរៀនសូត្រស្វែងយល់ដឹងរហូត |
|---|---|---|
| សិស្ស១នាក់ | រៀននូវអ្វីត្រូវរៀនតាមកម្រិតសមត្ថភាពរបស់ខ្លួន | រៀនពេញពេលនៅសាលារៀននិងផ្ទះ |
| ស្គាល់ខ្លួនឯង | ផ្តោតលើចរិយាធ្វើការងារ | ប្រើថាមពលពេលវេលាផ្តោតលើគោលបំណង |
| • គ្រប់គ្រងអត្តចរិតបាន ដោយភាពមិនខឹង ឬច្រឡោត | • សម្របតាមបរិបទ ដោយបំពេញការងារប្រចាំថ្ងៃ តាមកាលវិភាគ | • គិតជាក់លាក់ ផ្អែកលើហេតុការណ៍និងទិន្នន័យ |
| • គ្រប់គ្រងឥរិយាបទបាន ដោយភាពស្ងប់ស្ងៀម | • អត់ធ្មត់ និងតស៊ូ រហូតបញ្ចប់ការងារ | • ដោះស្រាយបញ្ហា ផ្អែកលើភាពសមហេតុផល និងភាពសព្វគ្រប់ |
| • មានសមត្ថភាពទំនាក់ទំនង ជាវិជ្ជមាន ដោយយល់ដឹងពីសង្គម | • ធនទ្រាំ ជាមួយអ្វីដែលលំបាក | • សម្រេចចិត្ត ធ្វើតែអ្វីដែលល្អ |
| មានចំណេះដឹងពីកិច្ចការ | ផ្តោតលើចរិយាមានសីលធម៌ | រៀនសូត្រស្វែងយល់ដឹងរហូត |
| • យល់ដឹងពីបញ្ញត្តិមេរៀន ក្នុងការងារនិងជីវិត | • សុចរិតភាព ដោយធ្វើតែអ្វីដែលត្រូវ | • សហប្រតិបត្តិការ ដោយផ្អែកលើច្បាប់ |
| • យល់ដឹងពីការរៀបចំបញ្ញត្តិមេរៀនសម្រាប់ការសិក្សាជាគម្រោង | • អត់ឱន ចំពោះអ្វីដែលកើតឡើង | • ទទួលខុសត្រូវបុគ្គល ជាសិស្ស ជាកូន ជាអ្នកដឹកនាំ |
| • យល់ដឹងពីការវិភាគ វាយតម្លៃ និងបង្កើតគំនិតថ្មី ពីការសិក្សាជាគម្រោង | • សុជីវធម៌ បញ្ជាក់ដោយការមានគណនេយ្យភាព | • ទទួលខុសត្រូវចំពោះសង្គម ដោយការជួយអ្នកក្រខ្សត់ |

43

## ឧបករណ៍ តារាងថ្នាក់រៀនមានដំណើរការ

| ថាមពលចំនួន១៖ ស្គាល់ខ្លួនឯង មានចំណេះដឹងពីកិច្ចការ | ថាមពលចរិយា៖ ផ្តោតលើចរិយាធ្វើការងារ និងចរិយាមានសីលធម៌ | ថាមពលពេលវេលា៖ ប្រើថាមពលពេលវេលាផ្តោតលើគោលបំណង និងរៀនសូត្រស្វែងយល់ដឹងរហូត |
|---|---|---|
| គ្រូបង្រៀន១នាក់ | បង្រៀននូវអ្វីត្រូវបង្រៀនតាមកម្រិតសមត្ថភាពសិស្ស | បង្រៀនពេញពេលនៅសាលានិងផ្ទះ |
| សិស្ស១នាក់ | រៀននូវអ្វីត្រូវរៀនតាមកម្រិតសមត្ថភាពរបស់ខ្លួន | រៀនពេញពេលនៅសាលានិងផ្ទះ |
| មាតាឬបិតា១នាក់ | ជួយកូននូវអ្វីដែលកូនត្រូវការ | ប្រើពេលវេលាទៀងទាត់ជួយកូន |
| គ្រួសារ១ | បញ្ហាសេដ្ឋកិច្ចនិងសង្គមបានដោះស្រាយ | អ្នកពាក់ព័ន្ធចំណាយពេលវេលាជួយ |
| មេភូមិ១ | សិស្សមករៀនទាន់ពេល | ផ្តោតរៀបចំនិងអនុវត្តយន្តការជួយសិស្ស |
| មេឃុំឬសង្កាត់១ | មានសុវត្ថិភាពសម្រាប់សិស្សមកសាលារៀន | ជួយសិស្សសង់សមត្ថភាពចិត្តសង្គម |
| គ្រូទទួលបន្ទុកថ្នាក់រៀន១ | សមធម៌សិក្សារៀនសូត្ររបស់សិស្សទាំងអស់ | សិស្សប្រើពេលវេលាជួយសិស្ស |
| នាយកសាលា១នាក់ | អនុវត្តអធិការកិច្ចការនិងគ្រប់គ្រងការអនុវត្តការងារជួយគ្រូបង្រៀន | ប្រើពេលវេលាជួយគ្រូទាន់ពេល |

44

